**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីរដ្ឋបាលក្នុងការចុះបញ្ជីម៉ាកនៅប្រទេសកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ស៊ី មាស**
**លីម លីហួ**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ទូរ សុខុម៉ា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី១២

ឆ្នាំចូលរៀន ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំករុណាអាត្មាភាពព្រះនាម **ស៊ី មាស** និង **លីម លីហួ** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈ ក្រុមP4C1 ជំនាន់ទី១២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៨-២០១៩ ។

សូមថ្លែងអំណរអរគុណ និងសម្តែងនូវកតញ្ញូតាធមិការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

+ លោកឪពុក អ្នកម្តាយ ទាំងពីរដែលលោកជាអ្នកមានគុណយ៉ាងធំធេង ចំពោះកូនដែលមានតម្លៃពុំអាចកាត់ថ្លៃបាន ព្រោះលោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សារូបកូនៗតាំងពីកូននៅក្នុងផ្ទៃឧទរនូវឡើយ ហើយពេលដែលកូនធំដឹងក្តីបន្តិចឡើង លោកទាំងពីរបានទូន្មានអប់រំប្រៀនប្រដៅ ដាស់តឿនកូនឱ្យប្រព្រឹត្តតែអំពើល្អ សេពគប់មិត្តភក្តិល្អជាដើម ម៉្យាងវិញទៀតលោកបានខិតខំធ្វើការទាំងថ្ងៃក្តៅ ថ្ងៃរងាត្រជាក់សព្វបែបយ៉ាង ដើម្បីបានថវិកាយកមកទំនុកបម្រុងការសិក្សារបស់កូន ព្រមទាំងផ្តល់ការស្រឡាញ់ ការថ្នាក់ថ្នម ភាពកក់ក្តៅ និងការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរដល់កូនៗទាំងអស់គ្នា ទាំងនេះគឺជាមហាគុណដ៏ធំធេង ដែលកូនពុំអាចបំភ្លេចបានឡើយនៅក្នុងជីវិតរបស់កូន ។

+ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូសាស្រ្តាចារ្យគ្រប់រូប នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ដោយទំនួលខុសត្រូវយ៉ាងខ្ពង់ខ្ពស់ ចំពោះការសិក្សារបស់និស្សិតទាំងអស់ ដោយលោកពុំគិតពីបញ្ហាការលំបាកនឿយហត់អ្វីឡើយ ផ្ទុយទៅវិញលោកខិតខំដាស់តឿន ទូន្មាន អប់រំសិស្ស-និស្សិតឱ្យខិតខំប្រឹងប្រែងសិក្សា ស្វែងរកចំណេះវិជ្ជាមកដាក់ខ្លួន និងពង្រឹងខ្លួនឯងធ្វើយ៉ាងណាឱ្យជាមនុស្សម្នាក់ដែលមានសមត្ថភាពពេញលេញដែលសង្គមគេត្រូវការជាដើម ។ លោកគ្រូ អ្នកគ្រូសាស្រ្តចារ្យគ្រប់រូប ក៏តែងតែខិតខំប្រឹងប្រែងក្នុងការសិក្សាស្រាវជ្រាវ រិះរកបេកគំហើញថ្មីៗ បន្ថែមដើម្បីផ្ទេរនូវពុទ្ធិ និងបទពិសោធន៍ដ៏ល្អៗដល់សិស្ស-និស្សិតគ្រប់គ្នាផង ។

+ ជាពិសេសយើងខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅដល់បណ្ឌិត **ទូរ សុខុម៉ា** ដែលជាសាស្រ្តចារ្យណែនាំរបស់យើងខ្ញុំទាំងពីរនាក់ ដែលតែងតែផ្តល់នូវគន្លឹះ ទ្រឹស្តី និងការអនុវត្តក្នុងការសិក្សាស្វែងយល់លើប្រធានបទរបស់យើងខ្ញុំ សាស្រ្តចារ្យមិនដែលរអ៊ូរទាំ ឬ មានភាពធុញទ្រាន់ចំពោះការផ្តល់នូវគំនិតយោបល់អ្វីឡើយ បើទោះបីជាមានការនឿយហត់ក្នុងការបំពេញការងារយ៉ាងណាក្តី ក៏សាស្រ្តចារ្យនៅតែផ្តល់ស្នាមញញឹម ហើយសប្បាយចិត្តពេលដែលឃើញសិស្ស-និស្សិតខិតខំសិក្សាស្រាវជ្រាវឯកសារនានាដែលពាក់ព័ន្ធលើប្រធានបទ សាស្រ្តចារ្យថែមទាំងព្យាយាមពន្យល់ណែនាំ និងប្រាប់នូវបទពិសោធន៍ល្អៗ ព្រមទាំងវិធីសាស្រ្តផ្សេងៗដែលទាក់ទងនឹងការសិក្សាស្រាវជ្រាវផងដែរ ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមជូនពរឱ្យលោកឪពុក អ្នកម្ដាយ ឯកឧត្ដមសាកលវិទ្យាធិការ ឯកឧត្តមសាកលវិទ្យាធិការរង លោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យ មិត្តនិស្សិត និងបុគ្គលិកដែលបម្រើការងារនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ មានតែសុខភាពល្អ សម្រេចបានជោគជ័យគ្រប់ភារកិច្ច និងសូមឱ្យសមប្រកបជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីក្លាយជាបការៈដទៃឡើយ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ ត្រូវនឹងថ្ងៃសុក្រ ១១រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ។

# អារម្ភកថា

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាសកលវិទ្យាល័យមួយដែលបានផ្តល់នូវជម្រកកក់ក្តៅដល់ខ្ញុំករុណាអាត្មាភាព **ស៊ឺ មាស** និង **លឹម លីហួ** រយៈពេលបួនឆ្នាំក្នុងការសិក្សាបរិញ្ញាបត្ររដ្ឋបាលសាធារណៈ ក្រៅពីការណែនាំ ទូន្មាន អប់រំ ប្រៀនប្រដៅ ពីសំណាក់លោកឪពុក អ្នកម្តាយ ដែលជាគ្រូដំបូងរបស់យើងខ្ញុំ ឬ/និងថាជាគ្រូទីមួយ ដែលបានផ្តល់នូវការជាស់តឿនបង្ហាត់បង្រៀន បង្ហាញផ្លូវល្អ ហើយយើងខ្ញុំពិតជាមានសំណាងដែលបានមកសិក្សាបន្តនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលជាសាកលវិទ្យាល័យមួយដែលយើងខ្ញុំប៉ងប្រាថ្នាថាពេលបញ្ចប់មធ្យមសិក្សាទុតិយភូមិ យើងខ្ញុំនឹងមកបន្តការសិក្សានៅទីនេះ ឥឡូវបំណងរបស់យើងខ្ញុំបានសម្រេច ហើយពិតជាមានភ័ព្វសំណាងណាស់ដែលបានមកជួបសាស្ត្រាចារ្យដែលមានចំណេះដឹង បទពិសោធន៍ ក្រមសីលធមិខ្ពស់ ក្នុងការបង្ហាត់បង្រៀន ការផ្ទេរនូវពុទ្ធិ ចែករំលែកនូវចំណេះដឹង និងការជាស់តឿនប្រកបដោយវិជ្ជាជីវៈហើយពុំដែលគិតពីការលំបាក ភាពនឿយហត់អ្វីឡើយ ។

នៅក្នុងផ្នែកមួយនៃការសិក្សាបរិញ្ញាបត្ររដ្ឋបាលសាធារណៈរយៈពេលបួនឆ្នាំ យើងខ្ញុំបានចាប់អារម្មណ៍លើប្រធានបទមួយដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា ដែលយើងខ្ញុំយល់ថា វិស័យពាណិជ្ជកម្មមួយនេះ វាបាននឹងកំពុងតែមានការលូតលាស់ និងកំពុងតែមានការប្រកួតប្រជែងយ៉ាងខ្លាំងក្លានូវលើពិភពលោក ជាពិសេសក្នុងប្រទេសដែលកំពុងអភិវឌ្ឍ តួយ៉ាងដូចជាប្រទេសកម្ពុជាយើងជាដើម ។ ម៉្យាងវិញទៀតប្រទេសកម្ពុជាយើងបាននឹងកំពុងតែប្រឈមមុខនឹងបញ្ហាមួយចំនួននៃការប្រកួតប្រជែងគ្នាលើផលិតផលនៃការនាំចូល នាំចេញ ព្រោះថាកម្ពុជាយើងគឺជាប្រទេសមួយដែលបានប្រកាន់យករបបទីផ្សារសេរី ដូច្នេះហើយការប្រកួតប្រជែងគ្នាលើវិស័យនេះ ជាហេតុដែលនាំឱ្យមានភាពមិនស្មោះត្រង់ចំពោះគ្នា ហើយក៏មានករណីនៃការក្លែងបន្លំនូវផលិតផលមួយចំនួនដែលជាហេតុបង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរ ។

ហេតុដូចនេះហើយបានយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី "នីតិវិធីរដ្ឋបាលក្នុងការចុះបញ្ជីម៉ាកនៅប្រទេសកម្ពុជា" មកធ្វើការសិក្សាស្រាវជ្រាវដើម្បីបានជាគន្លឹះ ឯកសារ និងចំណេះដឹងបន្ថែមដល់និស្សិតជំនាន់ក្រោយៗបន្តទៀត ។

បើទោះបីជាខ្លឹមសារទាំងស្រុងនៅក្នុងសៀវភៅសារណា ឬរបាយការណ៍កម្មសិក្សានេះមានការពិនិត្យយ៉ាងយកចិត្តទុកដាក់យ៉ាងណាក្តី យើងខ្ញុំគិតថាវានៅតែមាននូវចំណុចមួយចំនួន និងមានន័យខុសឆ្គង ឬ/និងអាចថាខុសនូវអក្ខរាវិរុទ្ធខ្លះ ដោយអចេតនា ឬការភ្លាំងភ្លេចខ្លះ ជាក់ជាមិនខានឡើយ តែទោះបីជាយ៉ាងណា យើងខ្ញុំទាំងពីរនាក់សូមទទួលនូវមតិរិះគន់ក្នុងន័យស្ថាបនាពី

សំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តអ្នកអាន មិត្តនិស្សិត ទាំងអស់គ្នា ដើម្បីឱ្យការសិក្សាស្រាវជ្រាវក្រោយទៀតកាន់តែមានភាពសុក្រិត និងល្អប្រសើរហើយទទួលបានផលប្រយោជន៍ច្រើនដល់មិត្តអ្នកអាន និងមិត្តនិស្សិតជំនាន់ខាងក្រោយៗទៀត ។ សូមអរគុណ!!!

# មាតិកា

**ទំព័រ**

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
៣. គោលបំណងនៃការស្រាវជ្រាវ ........ ៣
៤. ទំហំ និងដែនកំណត់ នៃការស្រាវជ្រាវ ........ ៥
៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៥
៦. វិធីសាស្ត្រស្រាវជ្រាវ ........ ៦
៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ ........ ៦

## ជំពូក ១
## មូលដ្ឋានច្បាប់ក្នុងការចុះបញ្ជីម៉ាក

១.១ ការកំណត់អត្ថន័យ ........ ៨
១.២ លក្ខខណ្ឌម៉ាកក្នុងការចុះបញ្ជីម៉ាក ........ ១០
១.២.១ ការកំណត់ប្រភេទម៉ាកក្នុងការចុះបញ្ជី ........ ១០
១.២.២ លក្ខខណ្ឌច្បាប់ក្នុងការចុះបញ្ជី ........ ១២
ក. នីតិវិធីចុះបញ្ជីម៉ាក ........ ១២
ខ. លក្ខខណ្ឌទម្រង់ ........ ១៣
១.៣ លក្ខខណ្ឌម៉ាកដែលមិនទទួលបានការចុះបញ្ជី ........ ១៧
១.៤ អានុភាពក្នុងការចុះបញ្ជីម៉ាក និងការបញ្ចប់សិទ្ធិលើម៉ាក ........ ១៨

## ជំពូក ២
## នីតិវិធីរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក

២.១ រចនាសម្ព័ន្ធនាយកដ្ឋានកម្មសិទ្ធិបញ្ញា ........ ១៩
២.២ នីតិវិធីរដ្ឋបាល ........ ២០
២.២.១ ការវិនិច្ឆ័យម៉ាក ........ ២០
ក. ការវិនិច្ឆ័យចំពោះម៉ាកធម្មតា ........ ២០

ខ. ការវិនិច្ឆ័យចំពោះពាណិជ្ជនាម ............................................................................................................ ២៣
គ. ការវិនិច្ឆ័យចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ................................................................................... ២៥
ឃ. ការវិនិច្ឆ័យចំពោះម៉ាកសមូហភាព ........................................................................................................... ២៦
២.២.២ សិទ្ធិ និងកាតព្វកិច្ចរបស់មន្ត្រីចុះបញ្ជីម៉ាក និងការពារម៉ាក ........................................................... ២៨
២.៣ ស្ថាប័នពាក់ព័ន្ធការពារម៉ាក ..................................................................................................................... ៣៣
២.៣.១ សិទ្ធិ និងកាតព្វកិច្ចស្ថាប័នពាក់ព័ន្ធក្នុងការការពារម៉ាក ........................................................................ ៣៣
ក. វិធានបណ្តោះអាសន្នរបស់ស្ថាប័នតុលាការ ............................................................................................. ៣៣
ខ. វិធានតាមច្រកព្រំដែនរបស់ស្ថាប័នគយ ..................................................................................................... ៣៤
២.៣.២ ទោសប្បញ្ញត្តិ ............................................................................................................................................. ៣៥

## ជំពូក ៣

## ពិភាក្សាលើនីតិវិធីរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក

៣.១ ពិភាក្សាលើលក្ខខណ្ឌនៃធាតុនីត្យានុកូល .................................................................................................... ៣៧
៣.២ ពិភាក្សាលើលក្ខខណ្ឌរដ្ឋបាល ...................................................................................................................... ៣៨
៣.៣ ចំណុចខ្លាំង និងចំណុចខ្សោយនៃការចុះបញ្ជីម៉ាក ......................................................................................... ៣៨
**សេចក្តីសន្និដ្ឋាន** ....................................................................................................................................... ៤០
**អនុសាសន៍** .........................................................................................................................................................
**ឯកសារពិគ្រោះ** ...................................................................................................................................................
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ជាការពិតណាស់ នៅពេលដែលបច្ចេកវិទ្យាលើពិភពលោកកាន់តែរីកចម្រើន បញ្ហាប្រឈម និងហានិភ័យនានាក៏កើតមានយ៉ាងច្រើនដើរមកទន្ទឹមគ្នាដែរ ។ ដោយឡែកប្រទេសកម្ពុជាដែលជាប្រទេសដែលកំពុងអភិវឌ្ឍ បានធ្លាប់ទទួលរងនូវផលវិបាកមួយចំនួនដោយសារការរីកដុះដាលលឿនពេកនៃបច្ចេកវិទ្យា ដោយកម្ពុជាគឺជាប្រទេសដែលទើបក្រោកពីសង្គ្រាមដ៏រ៉ាំរ៉ៃ ជាហេតុដែលបង្កឱ្យការវិវត្តន៍នៃប្រទេសមួយនេះ មានការយឺតយ៉ាវជាងបណ្តាប្រទេសដទៃផ្សេងទៀត ។ ក្រោយពីការរៀបចំកែប្រែប្រទេសក្រោមភ្លើងសង្គ្រាមដ៏សែនជូរជត់មកនៅឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំរចនាសម្ព័ន្ធថ្មីមួយដើម្បីគ្រប់គ្រងប្រទេស ហើយនៅឆ្នាំ១៩៩៦ រាជរដ្ឋាភិបាលក៏បានបង្កើតក្រសួងពាណិជ្ជកម្ម[1]ឡើង ដើម្បីលើកស្ទួយកិច្ចគាំពារគោលនយោបាយពាណិជ្ជកម្ម ដោយឈរលើមូលដ្ឋានច្បាប់ ជួយរកទីផ្សារឱ្យប្រជាពលរដ្ឋ ធានាឱ្យបាននូវផលប្រយោជន៍រួមសម្រាប់ប្រជាពលរដ្ឋទូទៅ ជាពិសេសចំពោះផលិតផល ឬ ទំនិញទាំងឡាយ ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនេះផ្ទាល់តែម្តង ។

ចំពោះប្រធានបទ "នីតិវិធីរដ្ឋបាលក្នុងការចុះបញ្ជីម៉ាកនៅប្រទេសកម្ពុជា" គឺជាប្រធានបទមួយដែលមានសារៈសំខាន់ណាស់ សម្រាប់សិស្ស-និស្សិតទូទៅក្នុងការសិក្សាស្រាវជ្រាវ ស្វែងយល់ពិសេស សម្រាប់ពាណិជ្ជករ អ្នកដែលមានស្នាដៃ ទេពកោសល្យ អាចបង្កើត ឬ ច្នៃប្រឌិតអ្វីមួយដែលជាផលប្រយោជន៍សម្រាប់សាធារណៈជន ហើយម្យ៉ាងបើសិនជាពួកគាត់មិនបានស្វែងយល់ពីផលប៉ះពាល់នៃការមិនបានចុះបញ្ជីម៉ាករបស់ខ្លួនទេ នោះពួកគាត់នឹងខាតបង់នូវប្រយោជន៍ ហើយបាក់ទឹកចិត្តក្នុងការស្វះស្វែងបង្កើតស្នាដៃថ្មី ព្រោះតែមានការរំលោភបំពានលើម៉ាករបស់ខ្លួនពីសំណាក់ជនដទៃដោយសារតែមិនបានចុះបញ្ជីម៉ាកត្រឹមត្រូវទៅតាមច្បាប់នៅក្រសួងពាណិជ្ជកម្ម ។

ប្រធានបទខាងលើពិតជាមានសារៈសំខាន់ និងរួមចំណែកយ៉ាងច្រើនសម្រាប់សាធារណៈជន ម៉្យាងវិញទៀតប្រធានបទនេះក៏បានចូលរួមក្នុងការលើកកម្ពស់ការយល់ដឹង សម្រាប់និស្សិតដែលកំពុងតែបន្តការសិក្សានៅតាមបណ្តាសាកលវិទ្យាល័យនានា និងចូលរួមលើកកម្ពស់ការរីកចម្រើនរបស់ប្រទេសកម្ពុជា ។ ជាសក្ខានុម័តបើទោះបីជាមានលិខិតបទដ្ឋានច្បាប់មួយចំនួនមានទាំងច្បាប់ជាតិ និងអន្តរជាតិ ដែលបាននឹងកំពុងតែទប់ស្កាត់រាល់ការរំលោភបំពានពីសំណាក់ជនដទៃយ៉ាងណាក្តីក៏ការក្លែងបន្លំនូវផលិតផល គុណភាពនៃផលិតផល និងឈ្មោះម៉ាកផលិតផលយ៉ាងណាក្តីក៏អំពើនៃការរំលោភបំពានម៉ាក និងការក្លែងបន្លំគុណភាពនៃផលិតផលនោះនៅតែបន្តកើតឡើង

[1] ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦។

ឬ/និងកើនឡើងជាបន្តបន្ទាប់ ។ តាមរយៈប្រធានបទខាងលើនេះ ខ្ញុំសង្ឃឹមថាវានឹងបានរួមចំណែកខ្លះក្នុងការកាត់បន្ថយការបំពានពីសំណាក់ជនដទៃក្រៅពីពាណិជ្ជករ ហើយនិងផ្តល់ជាពុទ្ធិថ្មីៗសម្រាប់ពាណិជ្ជករក្នុងការយល់ដឹងបន្ថែម ដើម្បីងាយស្រួលក្នុងការការពារផលិតផលរបស់ខ្លួន ឱ្យស្របទៅតាមច្បាប់ ទិន្នន័យទាំងនេះនឹងជាឯកសារបន្ថែម សម្រាប់និស្សិតជំនាន់ក្រោយទៀតក្នុងការសិក្សាស្រាវជ្រាវបន្ថែមទាក់ទងនិងប្រធានបទការចុះបញ្ជីម៉ាក ឱ្យកាន់តែធំទូលាយ ហើយប្រធានបទនេះទៀតសោត និងបានជាប្រទីបដ៏តូចមួយក្នុងការបំភ្លឺ ឆ្លើយតបនឹងបញ្ហាចោទមួយចំនួន ជុំវិញការបំពានម៉ាក និងការប្រកួតប្រជែងដែលគ្មានភាពស្មោះត្រង់នានា និងចូលរួមជាដំណោះស្រាយដល់បញ្ហាផ្សេងៗដែលទាក់ទងនឹងម៉ាក និងផលិតផលនេះផងដែរ ។ ប្រធានបទខាងលើនេះក៏ពិតជាមានសារៈសំខាន់ចាំបាច់ណាស់សម្រាប់និស្សិត និងអ្នកប្រកបរបរអាជីវកម្មនាពេលបច្ចុប្បន្ននេះ ព្រោះកាលណាការយល់ដឹងរបស់និស្សិតក្តី អ្នកប្រកបរបររកស៊ីក្តី ត្រូវតែទាក់ទងនឹងការចុះបញ្ជីម៉ាកនេះជានិច្ច បើសិនជាមានការយល់ដឹងតិចតួច ពីការចុះបញ្ជីការពារម៉ាកផលិតផលរបស់ខ្លួននោះផលិតផលទាំងនោះ វាងាយនឹងទទួលរងនូវហានិភ័យនៃការបំពានរបស់អ្នកដទៃដែលមានគំនិតទុច្ចរិតជាក់ជាមិនខាន ។

ដូច្នេះប្រធានបទនេះនឹងផ្តល់នូវខ្លឹមសារ និងផលប្រយោជន៍ជាច្រើនដល់អ្នកសិក្សា និងអ្នកដែលប្រកបអាជីវកម្មផ្សេងៗ ហើយអាចចូលរួមជាចំណែកនៃឯកសារសម្រាប់សិក្សាស្រាវជ្រាវដល់និស្សិតជំនាន់ក្រោយៗទៀត ។ តើប្រធានបទខាងលើនេះនឹងរួមចំណែកអ្វីខ្លះសម្រាប់ការការពារផលប្រយោជន៍ម្ចាស់ម៉ាកនៅប្រទេសកម្ពុជា ។ តើប្រធានបទនេះនឹងអាចមានផលប្រយោជន៍អ្វីខ្លះសម្រាប់សង្គមជាតិទាំងមូល ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នាពេលបច្ចុប្បន្នបញ្ហាជាច្រើន បាននឹងកំពុងតែមានការកើនឡើងជាបន្តបន្ទាប់ ដោយសារភាពទំនើបនៃបច្ចេកវិទ្យាសម័យថ្មី មានការរីកចម្រើនខ្លាំងក្លាលើសពីការគិត និងរំពឹងទុករបស់មនុស្សទូទៅ ។ ជាក់ស្តែងប្រទេសកម្ពុជាយើង ដែលជាប្រទេសកំពុងអភិវឌ្ឍន៍ហាក់ដូចជាពុំទាន់បានរៀបចំខ្លួនឱ្យទាន់សភាពការណ៍នៃភាពជឿនលឿននៃបច្ចេកវិទ្យានេះនៅឡើយ តែទោះបីយ៉ាងណាថ្នាក់ដឹកនាំប្រទេសគឺសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** កំពុងតែមានការខិតខំប្រឹងប្រែងស្វះស្វាយ៉ាងខ្លាំង ដើម្បីដឹកនាំនាវាកម្ពុជាឱ្យមានការវិវត្តន៍រីកចម្រើនឆ្ពោះទៅមុខ ។ បើទោះបីជាបច្ចុប្បន្ននេះបញ្ហាជាច្រើនបានកើតឡើង ជាពិសេសបញ្ហាទាក់ទងនឹងវិវាទផ្សេងៗដោយការមិនចុះបញ្ជីម៉ាកផលិតផលត្រឹមត្រូវទៅតាមច្បាប់កំណត់ ការក្លែងបន្លំម៉ាក ការលួចចម្លងស្នាដៃអ្នកដទៃ និងការរំលោភបំពានឈ្មោះនៃផលិតផលអ្នកដទៃក្តី វាហាក់ជារឿងមួយដែលកំពុងតែបង្កជាបញ្ហា និងការស្មុគស្មាញជាច្រើនដល់ផលិតករ ពាណិជ្ជករ និងមន្ត្រីដែលពាក់ព័ន្ធ ក៏ព្រោះតែការគិតអំពី

ប្រយោជន៍ផ្ទាល់ខ្លួនច្រើន បានធ្វើឱ្យមនុស្សមួយចំនួនមានភាពអាត្មានិយម ហើយរំលោភបំពានគ្នាទៅវិញទៅមក មិនតែប៉ុណ្ណោះការរកស៊ី និងការធ្វើអាជីវកម្មនានា មានការប្រកួតប្រជែងគ្នាដោយភាពមិនស្មោះត្រង់ ហើយវាបង្កជាហេតុផលលំបាកយ៉ាងច្រើនក្នុងសង្គមនាពេលបច្ចុប្បន្ននេះ ។

ទោះបីជាយ៉ាងណា រាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្ន និងថ្នាក់ដឹកនាំគ្រប់ក្រសួងពាក់ព័ន្ធនានា ជាពិសេសក្រសួងពាណិជ្ជកម្មដែលមានឯកឧត្តមរដ្ឋមន្ត្រី **ប៉ាន សូរស័ក្តិ** ដែលមានសមត្ថកិច្ចក្នុងការទទួលត្រូវខ្ពស់ក្នុងការគ្រប់គ្រងក្រសួងពាណិជ្ជកម្ម ហើយនាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលជាសេនាធិការផ្ទាល់របស់ក្រសួង ក៏មានតួនាទី និងភារកិច្ចក្នុងការដោះស្រាយបញ្ហាវិវាទ និងបញ្ហាប្រឈមផ្សេងៗមានការរំលោភបំពានម៉ាក ការលួចចម្លងស្នាដៃ ការលួចបន្លំឈ្មោះផលិតផលជាដើម។ តើនឹងមានផលប៉ះពាល់អ្វីខ្លះប្រសិនបើម្ចាស់អាជីវករផ្ទាល់មិនបានចុះបញ្ជីម៉ាកនៅក្រសួងពាណិជ្ជកម្ម? តើប្រសិទ្ធភាពក្នុងការចុះបញ្ជីម៉ាកអាចការពារផលប្រយោជន៍អ្វីខ្លះដល់ម្ចាស់អាជីវករ ឬពាណិជ្ជករ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះគោលបំណងនៃការស្រាវជ្រាវលើប្រធានបទនេះដោយក្រុមរបស់យើងខ្ញុំ មើលឃើញពីបញ្ហាមួយចំនួន ៖

ទី១ ដោយសារបច្ចុប្បន្នការគោរពច្បាប់ហាក់នូវមានកម្រិត ដូចដែរយើងបានឃើញហើយថាបើទោះបីជារាជរដ្ឋាភិបាលកម្ពុជាព្យាយាមទប់ស្កាត់ និងការពារយ៉ាងណាក្តី ក៏អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់នានាហាក់បន្តកើនឡើង ហើយបង្កជាផលវិបាកយ៉ាងច្រើនដល់សង្គមកម្ពុជានាពេលបច្ចុប្បន្ន ។ ជាការពិតណាស់ ការកើនឡើងនៃបញ្ហារំលោភបំពាននេះ វាជាផ្នែកមួយនៃកង្វះចំណេះដឹងរបស់ប្រជាពលរដ្ឋ ដោយពុំបានចុះបញ្ជីផលិតផលរបស់ខ្លួននៅក្នុងក្រសួងពាណិជ្ជកម្ម ហើយពេលខ្លះទៀត បើទោះបីជាបានចុះបញ្ជីខ្លះហើយក្តីក៏ការបំពានផ្សេងៗនូវតែកើតឡើង នេះក៏ព្រោះតែការអនុវត្តច្បាប់នូវមានកម្រិតនូវឡើយ ហេតុនេះការស្រាវជ្រាវលើប្រធានបទខាងលើនេះនឹងបានជាផ្នែកមួយនៃដំណោះស្រាយសម្រាប់បញ្ហាខាងលើនេះ ។

ទី២ ដោយសារតែការក្លែងបន្លំម៉ាក យើងដឹងហើយថាក្នុងមួយឆ្នាំៗ ការក្លែងបន្លំម៉ាកមានការកើនឡើងជាលំដាប់ ហើយការដោះស្រាយមួយចំនួនក៏ជាដំណោះស្រាយសម្រាប់កម្មសិទ្ធិករ ការក្លែងបន្លំម៉ាក និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ បាននឹងកំពុងតែមានការវិវត្តន៍កើនឡើងច្រើន និងបានធ្វើឱ្យកម្ពុជាបានជួបនូវបញ្ហាស្មុគស្មាញជាច្រើន ក្នុងនោះបញ្ហានេះបានបង្កផលវិបាកជាច្រើនម្ចាស់ពាណិជ្ជករផ្ទាល់ ដោយភាគច្រើនពួកគាត់មានការយល់ដឹងតិចតួចក្នុងការចុះបញ្ជីការពារម៉ាករបស់ខ្លួននៅក្រសួងពាណិជ្ជកម្ម ។ ដើម្បីការពារផលិតផលរបស់ពួកគាត់ជៀសវាងពីការក្លែងបន្លំ ពាណិជ្ជករដែលជាម្ចាស់ផលិតផល គួរទៅចុះបញ្ជីម៉ាករបស់ខ្លួនឱ្យស្របតាមច្បាប់ ។

ទី៣ ដោយសារតែការប្រកួតប្រជែងមិនស្មោះត្រង់ ការប្រកួតប្រជែងដោយទុច្ចរិត គឺជាអំពើដែលខុសច្បាប់ ព្រោះមហិច្ឆតារបស់មនុស្សម្នាក់ៗពុំមានដែនកំណត់ឡើយ ហើយទាក់ទងនឹងកត្តាផលប្រយោជន៍បុគ្គលដូច្នេះ ទើបមនុស្សភាគច្រើនមិនបានគិតពីគុណតម្លៃ និងផលប៉ះពាល់ ។ ការប្រកួតប្រជែងនេះទៀតសោត គឺធ្វើយ៉ាងណាដើម្បីឱ្យឈ្នះភាគីជាគូរបដិបក្ខរបស់ខ្លួន នេះក៏ជាមូលហេតុនៃការប្រកួតប្រជែងមិនស្មោះត្រង់ចំពោះគ្នាទៅវិញទៅមកដែរ ។

ទី៤ ដើម្បីរួមចំណែកក្នុងការការពារផលប្រយោជន៍ពាណិជ្ជករ ដោយសារតែឯកសារមួយចំនួន និងកង្វះនៃការស្រាវជ្រាវបន្ថែម ដូច្នេះពាណិជ្ជករ បើទោះបីជាមានស្នាដៃល្អក្នុងការផលិត ឬបង្កើតស្នាដៃផ្សេងៗក្តីក៏ស្នាដៃ និងផលិតផលនោះពុំបានស្ថិតនៅគង់វង្សដែរ មិនយូរមិនឆាប់នឹងមានគេក្លែងបន្លំ កង្វះឯកសារ និងពត៌មានទាក់ទងនឹងកម្មសិទ្ធិបញ្ញា គឺជាដើមចមដែលបង្កឱ្យម្ចាស់ពាណិជ្ជករផ្ទាល់ខ្វះការយកចិត្តទុកដាក់ និងការចុះបញ្ជីដើម្បីការពារផលិតផលរបស់ខ្លួន ។

ទី៥ ដើម្បីទុកជាស្នាដៃសម្រាប់និស្សិតជំនាន់ក្រោយ សិក្សាស្រាវជ្រាវលើប្រធានបទខាងលើវាគ្រាន់តែជ្រុងមួយនៃប្រធានបទនេះប៉ុណ្ណោះ ព្រោះទាក់ទងនឹងកម្មសិទ្ធិបញ្ញានេះ វាមានទំហំធំទូលាយហើយសង្ឃឹមថា វាអាចជាប្រទីបដ៏តូចមួយសម្រាប់និស្សិតជំនាន់ក្រោយសម្រាប់ស្រាវជ្រាវបន្ថែម និងពង្រីកន័យសេចក្តីនៃប្រធានបទ និងឱ្យកាន់តែធំទូលាយបន្ថែមទៀត ព្រោះកម្ពុជាយើងជាប្រទេសដែលប្រកាន់យករបបទីផ្សារសេរី ហេតុដូច្នេះលំហូរនៃការនាំចូលនូវផលិតផលផ្សេងៗមានច្រើន ហើយផលិតផលទាំងនោះបានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពអ្នកប្រើប្រាស់ និងបង្កជាផលវិបាកសម្រាប់សង្គមយើង ។ ហេតុដូច្នេះការសិក្សាស្រាវជ្រាវអំពីប្រធានបទខាងលើពិតជាមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះប្រធានបទនេះនឹងអាចជាចំណែកមួយនៃការយល់ដឹងរបស់ប្រជាពលរដ្ឋខ្មែរ និងនិស្សិតជាច្រើនដែលកំពុងតែសិក្សានៅតាមបណ្តាសាកលវិទ្យាល័យ ។ សម្រាប់ក្រុមខ្ញុំផ្ទាល់ ប្រធានបទនេះពិតជាមានសារៈសំខាន់ណាស់ ព្រោះថាការសិក្សារបស់និស្សិតភាគច្រើន ពុំទាន់បានស្វែងយល់ឱ្យមានភាពស៊ីជម្រៅទាក់ទងនឹងប្រធានបទនៃការចុះបញ្ជីម៉ាកនេះនៅឡើយ ហើយចំពោះប្រធានបទនេះវាគឺជាប្រធានបទមួយដែលថ្មីសម្រាប់ក្រុមខ្ញុំ ហើយក្រុមខ្ញុំនឹងព្យាយាមសិក្សាស្វែងយល់លើប្រធានបទនេះឱ្យបានល្អប្រសើរ ហើយស្វែងរកជាទិន្នន័យថ្មី និងឯកសារពាក់ព័ន្ធនានា ដើម្បីជាពន្លឺមួយសម្រាប់មិត្តនិស្សិតជំនាន់ខាងក្រោយសិក្សាស្រាវជ្រាវឱ្យកាន់តែសុក្រឹត និងធំទូលាយជាងនេះទៅទៀត ។

ចំពោះប្រធានបទខាងលើនេះ ពិតជាមានសារៈសំខាន់និងមានភាពចាំបាច់ណាស់សម្រាប់និស្សិត និងអ្នកប្រកបរបរអាជីវកម្មនាពេលបច្ចុប្បន្ននេះ ព្រោះកាលណាការយល់ដឹងរបស់និស្សិតក្តី អ្នកប្រកបរបររកស៊ីទាក់ទងនឹងការចុះបញ្ជីក្តី មានការយល់ដឹងតិចតួចពីការចុះបញ្ជីចុះបញ្ជី ការការពារម៉ាកផលិតផលរបស់ខ្លួន នោះធ្វើឱ្យផលិតផលរបស់ខ្លួនងាយនឹងទទួលរងនូវហានិភ័យនៃ

ការបំពានរបស់អ្នកដទៃដែលមានគំនិតទុច្ចរិត ។ ដូច្នេះចំពោះប្រធានបទនេះនឹងផ្តល់នូវខ្លឹមសារ និងប្រយោជន៍ជាច្រើនដល់អ្នកសិក្សា និងអ្នកដែលប្រកបអាជីវកម្មផ្សេងៗ ហើយពិសេសវានឹងចូលរួមជាចំណែកនៃឯកសារសិក្សាស្រាវជ្រាវដល់និស្សិតជំនាន់ក្រោយទៀតផងដែរ ។

## ៤. ទំហំ និងដែនកំណត់ នៃការស្រាវជ្រាវ

សម្រាប់ទំហំ នៃការស្រាវជ្រាវនេះ វាមានទំនាក់ទំនងជាមួយក្រសួងពាណិជ្ជកម្ម ជាពិសេសគឺនាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលមានសិទ្ធិ និងកាតព្វកិច្ចក្នុងការដោះស្រាយបញ្ហារាល់ផ្សេងៗដែលទាក់ទងនឹងម៉ាក និងច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២ ជាដើម ដោយប្រធានបទខាងលើមានភាពស៊ីជម្រៅ និងការចុះបញ្ជីម៉ាក ការការពារផលិតផលនានាសមស្របទៅតាមផ្លូវច្បាប់ ដូច្នេះខ្លឹមសារនៃប្រធានបទនេះផ្តោតសំខាន់លើះ

ទី១ ទាក់ទងនឹងវិធានគតិយុត្តនៃការចុះបញ្ជីម៉ាក

ទី២ ទាក់ទងនឹងលទ្ធផលនៃការចុះស្រាវជ្រាវនៅក្រសួងពាណិជ្ជកម្ម

ទី៣ ការពិភាក្សាលើប្រធានបទដែលបានស្រាវជ្រាវ ។

ចំពោះដែនកំណត់ នៃការស្រាវជ្រាវលើប្រធានបទនេះថាតើវិធានគតិយុត្តនៃការចុះបញ្ជីម៉ាកនេះមានសារៈសំខាន់អ្វីខ្លះ តើវាមានអានុភាពគតិយុត្តយ៉ាងដូចម្តេច ។ ចុះលទ្ធផលនៃការស្រាវជ្រាវផ្តល់ផលប្រយោជន៍អ្វីខ្លះដល់អ្នកសិក្សា ហើយតើយើងគួរពិភាក្សាដេញដោលគ្នាលើប្រធានបទនេះត្រង់ចំណុចណាខ្លះ និងផ្តល់ផលប្រយោជន៍អ្វីខ្លះ ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃប្រធានបទដែលក្រុមយើងខ្ញុំលើកមកធ្វើការសិក្សាស្រាវជ្រាវ ជាទូទៅយើងគិតពិចារណាលើចំណុចមួយចំនួនគឺ ៖

- មានសារៈសំខាន់ចំពោះសង្គម គឺផ្តល់ទំនុកទុកចិត្តពីអតិថិជនអន្តរជាតិអាចធ្វើវិនិយោគទុនមកធ្វើការវិនិយោគបន្តនៅកម្ពុជាកាន់តែច្រើនឡើង
- មានសារៈសំខាន់ចំពោះវិស័យសេដ្ឋកិច្ច ព្រោះវាបង្កើនទំនុកចិត្តពីពាណិជ្ជករ ហើយពួកគាត់និងចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មដើម្បីការពារផលិតផលរបស់ខ្លួនឱ្យស្របតាមច្បាប់
- មានសារៈសំខាន់ចំពោះប្រព័ន្ធច្បាប់នៅកម្ពុជា ព្រោះវានឹងធ្វើឱ្យច្បាប់នៅកម្ពុជាមានភាពល់នឹងល្អ ហើយពួកវិនិយោគទុនបរទេសនឹងជឿទុកចិត្តលើប្រព័ន្ធច្បាប់នៅកម្ពុជាហើយច្បាប់នៅកម្ពុជាកាន់តែមានកិត្យានុភាពល្អប្រសើរថែមទៀត
- សារៈសំខាន់ចំពោះយើងខ្ញុំ ចំពោះប្រធានបទនេះគឺនឹងបានជាប្រយោជន៍ច្រើន សម្រាប់យើងព្រោះថាបានសិក្សាស្រាវជ្រាវលើប្រធានបទនេះ ស្វែងយល់ពីខ្លឹមសារនៃប្រធានបទ

+ ពត៌មានផ្សេងដែលបានមកពីការស្រាវជ្រាវ បានជាបទពិសោធន៍ក្នុងការសរសេរ និងបំណិនបន្ថែមនូវក្នុងជីវិត ហើយទទួលបានភាពជោគជ័យក្នុងការទទួលបានសញ្ញាបត្រ ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវលើប្រធានបទនេះ ដើម្បីឱ្យលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ មានលក្ខណៈវិទ្យាសាស្ត្រ និងមានកម្រិតជឿជាក់អាចទទួលយកបាន។ កម្រិតនៃការជឿជាក់ផ្អែកលើទិន្នន័យ និងការវិភាគទិន្នន័យ។

*ការកំណត់អថេរ*

ជាបឋមយើងត្រូវកំណត់អថេរជាមុនសិន ដើម្បីកំណត់ទិសដៅស្វែងរកទិន្នន័យ។ អថេរមានពីរគឺ អថេរឯករាជ្យ និងអថេរមិនឯករាជ្យ ។

+ អថេរឯករាជ្យមានៈ ច្បាប់ និងបទដ្ឋានគតិយុត្តនានា (ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ អនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ជាដើម) ។
+ អថេរមិនឯករាជ្យ គឺ នីតិវិធីរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក ។

*ការប្រមូលទិន្នន័យ*

ការសិក្សាស្រាវជ្រាវនេះ យើងស្វែងទិន្នន័យដែលមានស្រាប់យកមកវិភាគ ។ ទិន្នន័យដែលយកមកសរសេរក្នុងរបាយការណ៍កម្មសិក្សានេះ គឺយកមកពី ឯកសារបណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបណ្ណាល័យផ្សេងៗទៀត ឯកសារមកពីក្រសួងពាណិជ្ជកម្ម រួមទាំងទិន្នន័យនិងពត៌មានដែលបានមកពី Google E-Book និង Youtube ជាដើម ។

ការស្រាវជ្រាវនេះ ក៏ស្វែងរកទិន្នន័យបឋមផងដែរ ដោយការសម្ភាសអ្នកជំនាញតាមទូរស័ព្ទជាមួយលោកសាស្ត្រាចារ្យ បណ្ឌិត **ជា ប៊ុនធៀង** ដែលជាមន្ត្រីជំនាញក្នុងនាយកដ្ឋានបុគ្គលិកនៃក្រសួងពាណិជ្ជកម្មទាក់ទងការអនុវត្តតាមនីតិវិធីច្បាប់ ឬបទដ្ឋាននានាក្នុងការចុះបញ្ជីម៉ាក។

*ការវិភាគទិន្នន័យ*

ទិន្នន័យដែលប្រមូលបានមកត្រូវវិភាគតាមបែបពិពណ៌នា ពីលក្ខខណ្ឌច្បាប់ ពីនីតិវិធីរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក និងអានុភាពម៉ាកដែលបានចុះបញ្ជី ក្នុងការការពារម៉ាកដែលបានចុះបញ្ជីរួចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ចំពោះរចនានៃការស្រាវជ្រាវនេះត្រូវបានចែកចេញជា១កថាខណ្ឌ និង៣ជំពូកគឺ ៖

កថាខណ្ឌទី១ និយាយអំពី៖ សេចក្តីផ្តើមដែលបរិយាយអំពី លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ ។

ជំពូកទី១៖ មូលដ្ឋានច្បាប់ក្នុងការចុះបញ្ជី បរិយាយអំពីការកំណត់អត្ថន័យ លក្ខខណ្ឌក្នុងការចុះបញ្ជីម៉ាក និងម៉ាកដែលមិនទទួលបានការចុះបញ្ជី។

ជំពូកទី២៖ នីតិវិធីរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក បរិយាយអំពីរចនាសម្ព័ន្ធនាយកដ្ឋានចុះបញ្ជីម៉ាក នីតិវិធីរដ្ឋបាល(ការវិនិច្ឆ័យម៉ាក សិទ្ធិនិងកាតព្វកិច្ចចុះបញ្ជីម៉ាក) ស្ថាប័នការពារម៉ាក(សិទ្ធិ និងកាតព្វកិច្ចរបស់ស្ថាប័នការពារម៉ាក និងទោសប្បញ្ញត្តិ)។

ជំពូកទី៣៖ ពិភាក្សាលើនីតិវិធីរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក ពិភាក្សាលើនៃធាតុនីត្យានុកូល ពិភាក្សាលើនីតិវិធីរដ្ឋបាននិងពីចំណុចខ្លាំងនិងខ្សោយក្នុងការចុះបញ្ជីម៉ាក។

# **ជំពូក ១**

# **មូលដ្ឋានច្បាប់ក្នុងការចុះបញ្ជីម៉ាក**

## **១.១ ការកំណត់អត្ថន័យ**

*ម៉ាក* គឺជាសញ្ញាដែលមើលឃើញហើយអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ ។ ម៉ាកដែលប្រើប្រាស់សម្រាប់ទំនិញហៅថា "**ពាណិជ្ជសញ្ញា**" ហើយម៉ាកដែលប្រើប្រាស់សម្រាប់សេវាហៅថា "**សេវាសញ្ញា**"[២]។

*ពាណិជ្ជសញ្ញា* គឺជាសញ្ញាប្រើប្រាស់សម្រាប់សម្គាល់ទំនិញ ដែលយើងមើលឃើញហើយក៏អាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ។ ម្យ៉ាងវិញទៀតពាណិជ្ជសញ្ញាត្រូវបានគេហៅជារួមថា "**ម៉ាក**" ។ អតិថិជនទូទៅអាចធ្វើការកត់សម្គាល់យ៉ាងងាយស្រួលនូវប្រភេទនៃម៉ាកពាណិជ្ជសញ្ញាដោយផ្អែកទៅលើទំនិញដែលបានបំពាក់ដោយម៉ាកនោះ[៣] ។

*សេវាសញ្ញា* គឺជាម៉ាកដែលប្រើប្រាស់សម្រាប់តែសេវាតែប៉ុណ្ណោះ ។ នៅក្នុងពាណិជ្ជកម្មសម័យទំនើប អតិថិជនជាច្រើនមិនមែនត្រឹមតែប្រឈមមុខជាមួយជម្រើសនៃតម្លៃទំនិញគ្រប់មុខទេ ប៉ុន្តែអតិថិជនក៏ត្រូវប្រឈមមុខផងដែរជាមួយនឹង ការកើនឡើងនៃប្រភេទសេវាជាច្រើនខុសៗគ្នាទាំងក្នុងកម្រិតជាតិ និងអន្តរជាតិ ។ ម្យ៉ាងវិញទៀតសព្វថ្ងៃនេះសេវាសញ្ញាហាក់ដូចជាមានការប្រកួតប្រជែងគ្នាជាខ្លាំងណាស់នៅក្នុងវិស័យពាណិជ្ជកម្ម ពីព្រោះតែសេវាគឺជាផ្នែកមួយដ៏សំខាន់ដែលអាចធ្វើឱ្យមានការទាក់ទាញអតិថិជន ។ មានន័យថាក្រុមហ៊ុននីមួយៗ ត្រូវការនូវសញ្ញាមួយដែលធ្វើឱ្យអតិថិជន អាចសម្គាល់នូវលក្ខណៈខុសគ្នារវាងសេវាទាំងនោះបានដូចជា ៖ សេវាក្រុមហ៊ុនធានារ៉ាប់រង សេវាក្រុមហ៊ុនជួលរថយន្ត សេវាក្រុមហ៊ុនដឹកជញ្ជូនជាដើម ។

សញ្ញាទាំងនេះហៅថា សេវាសញ្ញា ហើយសេវានេះមានតួនាទីយ៉ាងសំខាន់សម្រាប់ការបង្ហាញអំពីប្រភពដើម និងការខុសប្លែកគ្នានៃមុខងារសម្រាប់សេវាជាច្រើនផ្សេងទៀត ដូចជាពាណិជ្ជសញ្ញារបស់ទំនិញដែរ[៤] ។

*ម៉ាកសមូហភាព* គឺជាសញ្ញាដែលមើលឃើញ សំដៅលើការប្រើក្នុងការដាក់ពាក្យសុំចុះបញ្ជី ហើយអាចសម្គាល់នូវប្រភពដើមនៃទំនិញ ឬសេវា ឬសម្គាល់នូវចរិតលក្ខណៈរួមដទៃទៀត គិតទាំងគុណភាពនៃទំនិញ ឬសេវារបស់សហគ្រាសផ្សេងៗគ្នា ដែលប្រើសញ្ញានោះ ក្រោមការគ្រប់គ្រង

[២] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, នស/រកម/០២០២/០០៦, ០៧.កុម្ភៈ.២០០២, មាត្រា២ ចំណុច"ក"។

[៣] នី វិចិត្រ, *នីតិកម្មសិទ្ធិបញ្ញា (ភ្នំពេញ៖ ក្រុមហ៊ុនមេធាវី អេចប៊ីអេស ២០១៣)* ទំព័រ១៨៥។

[៤] ឥន យឿន និងអ៊ុក វណ្ណារ័ត្ន, *នីតិកម្មសិទ្ធិបញ្ញា (ភ្នំពេញ ២០១៣)*, ទំព័រ ៧២។

របស់ម្ចាស់ម៉ាកសមូហភាពដែលបានចុះបញ្ជី[៥] ។ម៉ាកសមូហភាព ជាម៉ាកដែលអនុញ្ញាតឱ្យប្រើប្រាស់បានតែអ្នកដែលជាសមាជិកអង្គការសមូហភាពណាមួយតែប៉ុណ្ណោះ ។ អង្គការនេះអាចជាសហាគមឬសហប្រតិបត្តិការនៃផលិតករ ឬពាណិជ្ជករ ។ ម៉ាកសមូហភាព ត្រូវបានកាន់កាប់ដោយសមាគមដែលសមាគមនោះមិនត្រូវប្រើប្រាស់ម៉ាកសមូហនាមនោះទេ ប៉ុន្តែសមាជិកនៅក្នុងសមាគមអាចប្រើប្រាស់ដោយគោរពទៅតាមការកំណត់ ។ ម៉ាកសមូហភាព ផ្ដែកសំខាន់លើការប្រើប្រាស់គ្រប់គ្រងរួមរបស់ម្ចាស់ម៉ាក ដោយមានការទទួលខុសត្រូវខ្ពស់ទាក់ទងទៅនឹងគុណភាពនៃសេវារបស់ទំនិញ ។

លក្ខណៈពិសេសរបស់ម៉ាកសមូហភាព មិនសំដៅលើការបញ្ជាក់ពីលក្ខណៈដើមរបស់ទំនិញ ឬសេវា ដែលមកពីសហគ្រាសពិសេសណានោះទេ ប៉ុន្តែម៉ាកសមូហភាពត្រូវបានគេប្រើអក្សរអង់គ្លេសកាត់ប្រើប្រាស់ដោយសហគ្រាសខុសៗគ្នា[៦] ។

***ពាណិជ្ជនាម*** គឺជាឈ្មោះ ឬសញ្ញាសម្គាល់ ឬជាឈ្មោះ និងសញ្ញាសម្គាល់សម្រាប់បញ្ជាក់ និងសម្គាល់លក្ខណៈខុសៗគ្នានៃសហគ្រាសនីមួយៗ[៧] ។

ពាណិជ្ជនាមមានដូចជា៖ (១)ឈ្មោះរបស់រូបវន្តបុគ្គល (២)ហេស្សនាម (៣)តាមការស្រមើស្រមៃ ជាឧទាហរណ៍៖ ក្រុមហ៊ុនគោជល់ មានសញ្ញារូបគោពណ៌លឿងជល់គ្នា ដែលអតិថិជនគ្រាន់តែឮពាណិជ្ជនាមនេះ អាចមានការស្រមើស្រមៃមួយនាំមកនូវភាពទាក់ទាញ ។ រាល់ឈ្មោះនាមករណ៍របស់រូបវន្តបុគ្គលដែលគេចាត់ទុកថាមិនសមរម្យ មិនអាចបែងចែកពីភាពខុសគ្នានៃសហគ្រាសនោះមិនអាចអនុញ្ញាតឱ្យត្រូវប្រើប្រាស់បានឡើយ ។ ពាណិជ្ជនាមដែលយើងឃើញប្រើប្រាស់ជាញឹកញយ ភាគច្រើនជាឈ្មោះរបស់រូបវន្តបុគ្គល ដែលជាឈ្មោះសហគ្រាស ឬក្រុមហ៊ុនឬពាណិជ្ជករជាដើម ។ ការប្រើប្រាស់បែបនេះ ជានិច្ចជាកាលយើងបានជួបប្រទះនូវឈ្មោះដូចគ្នា ឬប្រហាក់ប្រហែលគ្នា ឬស្រដៀងគ្នា ដែលអាចមានការភ័ន្តច្រឡំ ។

សព្វថ្ងៃនេះយើងសង្កេតឃើញមាន ក្រុមហ៊ុន ហាងជាច្រើន ឬភោជនីយដ្ឋានដែលដាក់យីហោស្រដៀងគ្នា ប្រហាក់ប្រហែលគ្នាជាច្រើនចំពោះ មុខរបរដូចគ្នា ឬសេវាដូចគ្នា "ហេង ហេង, ប៉េង ហេង, សេង លាង, ........" ។ ថ្វីត្បិតតែវាមិនដូចគ្នាមែន ប៉ុន្តែវាអាចនឹងកើតមានការភ័ន្តច្រឡំពីសំណាក់អ្នកប្រើប្រាស់ ប្រសិនបើមិនបានពិនិត្យឱ្យបានច្បាស់ ។ ម្យ៉ាងវិញទៀត ការប្រើប្រាស់ពាណិជ្ជនាមលើផលិតផល ឬសេវា គឺជាបញ្ហាមួយដែលម្ចាស់សហគ្រាស ឬក្រុមហ៊ុន ត្រូវយកចិត្ត

---

[៥] ច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, នស/រកម/០២០២/០០៦, ០៧.កុម្ភៈ.២០០២, មាត្រា២ ចំណុច"ខ"។

[៦] ឥន ឿន និងអ៊ុក វណ្ណារ័ត្ន, *នីតិកម្មសិទ្ធិបញ្ញា (ភ្នំពេញ ២០១៣)*, ទំព័រ ៦៧។

[៧] ច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, នស/រកម/០២០២/០០៦, ០៧.កុម្ភៈ.២០០២, មាត្រា២ ចំណុច"គ"។

ទុកដាក់ក្នុងការប្រើប្រាស់លើឈ្មោះរបស់ខ្លួន ដើម្បីសម្គាល់ទំនិញ ឬសេវា ងាយនឹងនាំឱ្យមានការភ័ន្តច្រឡំ ពីព្រោះឈ្មោះមនុស្សភាគច្រើនគឺដូចគ្នា ស្រដៀងគ្នា ឬប្រហាក់ប្រហែលគ្នា[៨] ។ ដូចនេះហើយដើម្បីឱ្យពាណិជ្ជនាមមានលក្ខណៈ ប្លែក និងគួរឱ្យចាប់អារម្មណ៍ពីសំណាក់អតិថិជននោះតម្រូវឱ្យបណ្តាម្ចាស់សហគ្រាសទាំងអស់ គួរណាស់តែជ្រើសរើសពាណិជ្ជនាមដែលប្លែកពីគេជាមុន មិនស្រដៀងគ្នានោះនឹងមានការចាប់អារម្មណ៍ ជាពិសេសមិនមានការភ័ន្តច្រឡំ ឬមិនមានបញ្ហានៅពេលក្រោយ ។

*និវេសនដ្ឋាន៖ ជាជនដែលរស់នៅក្នុងប្រទេសកម្ពុជាចាប់ពី១៨០ថ្ងៃឡើង ក្នុងមួយឆ្នាំ ។*

## ១.២ លក្ខខណ្ឌម៉ាកក្នុងការចុះបញ្ជីម៉ាក

កន្លងមកនៅកម្ពុជាមានការចុះបញ្ជីម៉ាកជាច្រើន ហើយម៉ាកទាំងនោះមានទម្រង់ខុសៗគ្នាទៅតាមការកំណត់របស់អ្នកស្នើសុំចុះបញ្ជី ។ ម៉ាកដែលបានចុះបញ្ជីទាំងនោះរួមមានដូចជា "ពាក្យ, អក្សរ, និមិត្តសញ្ញា, ស្លាកសញ្ញា, ឈ្មោះ និងហត្ថលេខា" ដែលកត្តាសំខាន់គឺការមើលឃើញហើយអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវា ។ ដូចនេះ យើងអាចសន្និដ្ឋានបានថាវាមានមុខងារចម្បង គឺធ្វើឱ្យអតិថិជនអាចសម្គាល់ ផលិតផល ទំនិញ ឬសេវា របស់ក្រុមហ៊ុនណាមួយ ហើយអាចញែកផលិតផលនោះទៅនឹងផលិតផលដែលស្រដៀងផលិតផលដោយគួរប្រកួតប្រជែង ។

### ១.២.១ ការកំណត់ប្រភេទម៉ាកក្នុងការចុះបញ្ជី

បែបបទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ការសុំប្តូរអាសយដ្ឋាននៃម្ចាស់ម៉ាក និងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាកត្រូវបានកំណត់ខាងក្រោម[៩] ៖

ក. ការស្នើសុំចុះបញ្ជីម៉ាក ការសុំប្តូរអាសយដ្ឋាននៃម្ចាស់ម៉ាក និងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាកត្រូវធ្វើនៅក្រសួងពាណិជ្ជកម្ម ។

ពាក្យស្នើសុំត្រូវភ្ជាប់មកជាមួយនូវ ៖

១. គំរូម៉ាក

២.បញ្ជីទំនិញ ឬសេវាត្រូវចុះបញ្ជីដោយរាយលំអិតតាមក្រុមមុខទំនិញ ទៅតាមចំណាត់ថ្នាក់អន្តរជាតិ ដូចមានក្នុងឧបសម្ព័ន្ធនៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់ ។

ខ. ការស្នើសុំចុះបញ្ជីម៉ាក ការសុំប្តូរអាសយដ្ឋាននៃម្ចាស់ម៉ាក និងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក ត្រូវបង់កម្រៃតាមការកំណត់នៅក្នុងសេចក្តីប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

---

[៨] ឥន យឿន និងអ៊ុក វណ្ណារ័ត្ន, *នីតិកម្មសិទ្ធិបញ្ញា (ភ្នំពេញ ២០១៣)*, ទំព័រ ៥៩។

[៩] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, នស/រកម/០២០២/០០៦, ០៧.កុម្ភៈ.២០០២, មាត្រា៥។

ការផ្តល់គំរូម៉ាក

គំរូមួយដែលមានលក្ខណៈសមស្រប ចំពោះការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកដើម្បីធ្វើឱ្យមន្ត្រីកាន់កាប់បញ្ជីងាយស្រួលក្នុងការចុះបញ្ជី[១០] ។ មានន័យថា គំរូម៉ាកនេះគឺធ្វើទៅតាមច្បាប់កំណត់មិនចេះតែដាក់តាមចិត្តនឹកឃើញនោះទេ ។ ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកត្រូវភ្ជាប់មកជាមួយនូវគំរូក្រាហ្វិចជាប់ច្បាស់លាស់ និងមិនរលុបម៉ាកនោះទេ ។

គំរូក្រាហ្វិចរបស់ម៉ាកមិនត្រូវមានទំហំលើសពី **៨សង់ទីម៉ែត្រគុណនឹង៨សង់ទីម៉ែត្រនោះទេ** (8×8)cm ។ ចំពោះគ្រប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក គេត្រូវភ្ជាប់មកជាមួយនូវគំរូក្រាហ្វិចរបស់ម៉ាកចំនួន ១៥ គំរូទៀតជាបន្ថែម សម្រាប់ការដាក់ពាក្យចុះបញ្ជីម៉ាកនៅក្នុងចំណាត់ថ្នាក់នីមួយៗ ។

គំរូក្រាហ្វិចទាំងនេះរបស់ម៉ាកចាំបាច់ត្រូវតែដូចគ្នាបេះបិទ ។ គំរូក្រាហ្វិចដែលភ្ជាប់ជាមួយនេះត្រូវតែជាគំរូដែលបង្ហាញច្បាស់លាស់នូវគ្រប់លក្ខណៈលំអិតរបស់ម៉ាក ហើយអាចធ្វើឱ្យការចម្លងបានច្បាស់លាស់ត្រឹមត្រូវពីគំរូនេះទៀតផង ។ បើសិនមានលក្ខណៈលំអិតណាមួយ មិនច្បាស់លាស់ ការិយាល័យចុះបញ្ជីម៉ាកអាចធ្វើការស្នើសុំគំរូម៉ាកនោះបន្ថែម ។ ប្រសិនបើមានការដាក់ពាក្យស្នើសុំចុះបញ្ជី ត្រូវធ្វើឡើងចំពោះចំណាត់ថ្នាក់លើសពីមួយថ្នាក់ នោះគេត្រូវដាក់ជូនបន្ថែមនូវគំរូម៉ាកចំនួន ១៥ ទៀតសម្រាប់ចំណាត់ថ្នាក់នីមួយៗ ។

ការប្រើប្រាស់ភាសាចំពោះម៉ាកក្នុងការដាក់ពាក្យសុំចុះបញ្ជី ឬឯកសារដែលពាក់ព័ន្ធផ្សេងៗត្រូវធ្វើឡើងជាភាសាខ្មែរ ឬអង់គ្លេស ។ ឯកសារដែលប្រើប្រាស់អមមកជាមួយពាក្យស្នើសុំចុះបញ្ជីដែលមិនមានជាភាសាខ្មែរ ឬអង់គ្លេស ត្រូវតែមានឯកសារបកប្រែអមមកជាមួយផង ។

ចំណាត់ថ្នាក់ ៖ នៅក្នុងការចុះបញ្ជីម៉ាក ម្ចាស់កម្មសិទ្ធិលើម៉ាកត្រូវតែពិពណ៌នាពីទំនិញ ឬសេវាទៅតាមចំណាត់ថ្នាក់ ដើម្បីងាយស្រួលដល់មន្ត្រីទទួលភារៈកិច្ចក្នុងការចុះបញ្ជី ។ ម្យ៉ាងទៀតយើងអាចដឹងថាចំណាត់ថ្នាក់នៃម៉ាកគឺមាន **៤៥ ចំណាត់ថ្នាក់ដែលក្នុងនោះគេចែកចេញជា ៣៤ ចំណាត់ថ្នាក់ជាទំនិញ និង ១១ ចំណាត់ថ្នាក់ជាសេវា**។

នៅក្នុងការចុះបញ្ជីមន្ត្រីកាន់កាប់បញ្ជីត្រូវអនុវត្តតាមចំណាត់ថ្នាក់អន្តរជាតិនៃទំនិញ ឬសេវានៃការចុះបញ្ជីម៉ាក[១១] មានន័យថា ព្រះរាជាណាចក្រកម្ពុជាមិនមានច្បាប់ណាមួយ ដែលកំណត់ឱ្យច្បាស់លាស់អំពីចំណាត់ថ្នាក់នៃម៉ាកនេះទេ ។ ហេតុនេះត្រូវធ្វើតាមកិច្ចព្រមព្រៀងទីក្រុងនីស ១៩៥៧ ។

---

[១០] មាត្រា១១ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ ២០០៦។

[១១] មាត្រា៩ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជកម្ម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០៦ ក្នុងការចុះបញ្ជី និងបោះពុម្ពផ្សាយម៉ាក មន្ត្រីកាន់កាប់បញ្ជីតម្រូវអនុវត្តតាម ចំណាត់ថ្នាក់អន្តរជាតិនៃទំនិញ ឬសេវានៃការចុះបញ្ជីម៉ាក ដែលអនុម័តដោយកិច្ចពញ្ញមព្រៀងទីក្រុងនីស ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ១៩៥៧ ហើយដែលចំណាត់ថ្នាក់នេះ បានធ្វើវិសោធនកម្មជាបន្តបន្ទាប់ ។

មន្ត្រីដែលទទួលភារៈកិច្ចពិនិត្យបែបបទផ្លូវការនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវធ្វើការបញ្ជាក់ពីប្រភេទដែលមាននៅក្នុងពាក្យស្នើសុំនោះ ដោយប្រើប្រាស់តែពាក្យពេចន៍ដែលគេប្រើនៅក្នុងតារាងអក្ខរៈក្រម ចំណាត់ថ្នាក់អន្តរជាតិទីក្រុងនីស ឬខ្ទង់លេខនៃចំណាត់ថ្នាក់ ។ ប្រសិនបើក្នុងខណៈពេលដែលលេខសម្គាល់នោះមិនត្រូវបានផ្តល់ឱ្យសម្រាប់ទំនិញ ឬសេវានីមួយៗនៅក្នុងពាក្យសុំចុះបញ្ជីទេ នោះអ្នកដាក់ពាក្យសុំនិងត្រូវបានស្នើឱ្យផ្តល់នូវលេខចំណាត់ថ្នាក់ដែលពាក់ព័ន្ធទាំងនោះ ។

ឧទាហរណ៍ ៖ ពាក្យសុំចុះបញ្ជីម៉ាកមួយ ដែលធ្វើឡើងដោយយកមនុស្សម្នាក់សម្រាប់ទំនិញចំណាត់ថ្នាក់លេខ៣ អាចត្រូវបានគេបញ្ជាក់ឈ្មោះទំនិញដូចតទៅ៖ សារធាតុសម្រាប់ការលាងសម្អាត (W00៦២) សារធាតុសម្រាប់ការជំរះប្តូរពណ៌ (B0៤៥៥) គ្រឿងសំអាង (C0៩៣៩) ប្រេងចម្រាញ់(E0១៧២) ប្រេងសំអាងសម្រាប់ប្រើប្រាស់ក្នុងគោលដៅគ្រឿងសំអាង (L0៣២) ។

### ១.២.២ លក្ខខណ្ឌច្បាប់ក្នុងការចុះបញ្ជី

#### ក. នីតិវិធីចុះបញ្ជីម៉ាក

រាល់ម៉ាកដែលមិនបានបញ្ញាត្តិនៅក្នុងមាត្រា ៤ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់លេខ នស/រកម/0២0២/00៦ ចុះថ្ងៃទី0៧ ខែកុម្ភៈ ឆ្នាំ២00២ ជាម៉ាកដែលអាចចុះបញ្ជីបានទាំងអស់ ។ ដូចនេះម៉ាកទាំងនោះមានសិទ្ធិក្នុងការសុំចុះបញ្ជីម៉ាកបានការដាក់ពាក្យស្នើសុំត្រូវធ្វើឡើងដោយម្ចាស់ម៉ាក[១២] ឬ អ្នកតំណាងម្ចាស់ម៉ាកផ្តល់សិទ្ធិឱ្យ[១៣] និងធ្វើតាមរយៈគំរូពាក្យស្នើសុំចុះបញ្ជីម៉ាក ដូចមានចែងនៅក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ដោយក្នុងពាក្យនោះត្រូវចុះហត្ថលេខាដោយម្ចាស់ម៉ាក ឬអ្នកតំណាងស្របច្បាប់ ។ ពាក្យស្នើសុំមួយអាចស្នើសុំចុះបញ្ជីម៉ាកមួយចំពោះទំនិញ ឬសេវាកម្មក្នុងចំណាត់ថ្នាក់តែមួយ ឬច្រើនតាមចំណាត់ថ្នាក់អន្តរជាតិ ។ នៅក្នុងច្បាប់ស្តីពីម៉ាកបានបញ្ញាត្តិថា "បុគ្គលគ្រប់រូបមានសិទ្ធិក្នុងការចុះបញ្ជីម៉ាកនេះមានន័យថានីតិបុគ្គល សហគ្រាស ឬរូបវន្តបុគ្គលទាំងអស់មានសិទ្ធិដាក់ពាក្យសុំចុះបញ្ជីម៉ាក លើកលែងតែជនបរទេសដែលច្បាប់ម៉ាក មិនអនុញ្ញាតឱ្យដាក់ពាក្យចុះបញ្ជីដោយផ្ទាល់បានទេ" ។ ទោះបីជាជនបរទេសមិនអាចដាក់ពាក្យចុះបញ្ជីម៉ាកដោយខ្លួនឯងក៏ដោយ ប៉ុន្តែពួកគេមានសិទ្ធិដាក់ពាក្យសុំចុះបញ្ជីម៉ាក តាមរយៈភ្នាក់ងារម៉ាកដែលមានទីលំនៅ និងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា[១៤] ។

---

[១២] គំរូពាក្យ ក្នុងឧបសម្ព័ន្ធ។

[១៣] គំរូពាក្យ ក្នុងឧបសម្ព័ន្ធ។

[១៤] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, នស/រកម/0២0២/00៦, 0៧.កុម្ភៈ.២00២, មាត្រា៥៨។

**ខ. លក្ខខណ្ឌទម្រង់**

ជំហានដំបូងក្នុងការចុះបញ្ជីម៉ាក អ្នកត្រូវតែទៅសូមគំរូពាក្យស្នើសុំដែលបោះពុម្ពរួចដោយឥតគិតថ្លៃ ពីមន្ត្រីកាន់កាប់បញ្ជី[១៥] បន្ទាប់មកបំពេញពាក្យស្នើសុំចុះបញ្ជីម៉ាក ដូចដែលមាននៅក្នុងគំរូនៃពាក្យស្នើសុំ ហើយពាក្យដែលបានបំពេញ និងភ្ជាប់មកជាមួយនូវៈ (១)ឈ្មោះរបស់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក (២)អាសយដ្ឋានទំនាក់ទំនង (៣)គំរូម៉ាកដែលស្នើសុំចុះបញ្ជី (៣)យថាប្រភេទរបស់ទំនិញ ឬសេវាដែលស្នើសុំចុះបញ្ជីក្នុងចំណោមថ្នាក់នីមួយៗ (៤)កម្រៃនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលតម្រូវសម្រាប់ ចំណាត់ថ្នាក់នីមួយៗ នៃទំនិញ ឬសេវាកម្មដែលស្នើសុំចុះបញ្ជីម៉ាក[១៦] ។

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក គឺជាបុគ្គលដែលទាមទារការគ្រប់គ្រងទៅលើម៉ាកនោះដែលក្លាយជាម្ចាស់កម្មសិទ្ធិលើម៉ាក ហើយបុគ្គលទាំងនោះអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល ។ ម្យ៉ាងវិញទៀត បុគ្គលនោះចាំបាច់ត្រូវតែៈ (១)ការប្រើប្រាស់ ឬមានបំណងប្រើប្រាស់ម៉ាកនៅកម្ពុជា (២)ផ្តល់អាជ្ញាប័ណ្ណឱ្យប្រើប្រាស់ម៉ាករបស់ខ្លួននៅកម្ពុជា (៣)មានបំណងផ្ទេរម្ចាស់កម្មសិទ្ធិទៅឱ្យបុគ្គលផ្សេង ដែលនឹងប្រើប្រាស់ម៉ាកនេះនៅកម្ពុជា ។

អ្នកដាក់ពាក្យស្នើសុំជារូបវន្តបុគ្គលត្រូវតែបញ្ជាក់ឱ្យច្បាស់នូវៈ (១)គោត្តនាម និងនាមខ្លួន (២)អាសយដ្ឋាន (៣)សញ្ជាតិ (៤)និវេសនដ្ឋាន ។

ចំពោះអ្នកដាក់ពាក្យស្នើសុំជានីតិបុគ្គលវិញ វាមិនខុសពីអ្នកដាក់ពាក្យជារូបវន្តបុគ្គលនោះទេ គឺត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួនដែរៈ (១)ឈ្មោះពេញរបស់ក្រុមហ៊ុន (២)អាសយដ្ឋាន ។

អ្នកដាក់ពាក្យស្នើសុំដែលម្ចាស់កម្មសិទ្ធិជាអង្គការ ឬសមាគម ក៏ត្រូវបំពេញឈ្មោះអង្គការ ឬសមាគម និងអាសយដ្ឋានរបស់អង្គការ ឬសមាគមនោះដែរ ដូចទៅនិងនីតិបុគ្គល ។ ម្យ៉ាងវិញទៀតម្ចាស់កម្មសិទ្ធិជាស្ថាប័នរាជរដ្ឋាភិបាល គឺត្រូវតែបំពេញឈ្មោះរបស់នាយកដ្ឋាន ឬក្រសួង និងអាសយដ្ឋានដែរ ។

នៅក្នុងលក្ខខណ្ឌម្ចាស់កម្មសិទ្ធិដែលមានគ្នាច្រើន ឬដៃគូរច្រើន វាមិនខុសអ្វីពីម្ចាស់កម្មសិទ្ធិជានីតិបុគ្គល និងរូបវន្តបុគ្គលនោះទេ គឺត្រូវបំពេញនូវលក្ខខណ្ឌដែលច្បាប់បានកំណត់ដូចជា ៖ (១)ត្រូវផ្តល់ឈ្មោះរបស់ដៃគូរនីមួយៗ (២)អាសយដ្ឋានរបស់បុគ្គលនីមួយៗ

---

[១៥] មាត្រា៣ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាំណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ ២០០៦។

[១៦] មាត្រា១៦ ចំណុចទី៣ អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០៦។

ទាក់ទងនឹងចំណុចនេះវាមានន័យថា រូបវន្តបុគ្គលក្តី នីតិបុគ្គលក្តី សមាគម ឬ អង្គការក្តី អាចដាក់ឈ្មោះរួម ឬតែឯងបាន ។ ប្រសិនបើសមាជិកដៃគូរយល់ព្រម ហើយមានលក្ខណៈគ្រប់គ្រាន់ដែលច្បាប់ទទួលស្គាល់ប៉ុណ្ណោះ ប៉ុន្តែចំពោះអាសយដ្ឋានវិញ គឺត្រូវតែយកអាសយដ្ឋានមួយណាដែលច្បាស់លាស់បំផុត មិនអាចប្រើប្រាស់អាស្រ័យគ្នាច្រើនបាននោះទេ ព្រោះវាធ្វើឱ្យមានការលំបាកក្នុងការទំនាក់ទំនង ។

***សិទ្ធិអាទិភាព*** ក្នុងការចុះបញ្ជីម៉ាកត្រូវបានផ្តល់តាមលក្ខខណ្ឌដូចខាងក្រោម[១៧]៖

ក. អ្នកស្នើសុំចុះបញ្ជីអាចស្នើសុំអាទិភាព នៃការចុះបញ្ជីដោយអមមកជាមួយនូវប្រកាសស្តីពីអាទិភាពដែលខ្លួនមានតាមរយៈការស្នើសុំចុះបញ្ជី នៅប្រទេសណាមួយដែលជាសមាជិកនៃអនុសញ្ញាទីក្រុងប៉ារីស ។

ខ. តម្លៃនៃប្រកាសស្តីពីអាទិភាពខាងលើ ត្រូវតែស្របទៅតាមលក្ខខណ្ឌដែលមាននៅក្នុងអនុសញ្ញាប៉ារីស ។

សិទ្ធិអាទិភាពនេះ វាទាក់ទងទៅនឹងការដាក់ពាក្យស្នើសុំចុះបញ្ជីមុនគេ ដើម្បីការពារនូវផលប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិកុំឱ្យមានការបំពាន ។ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម្នាក់បានដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកចំពោះម៉ាកដូចគ្នា ដែលត្រូវប្រើប្រាស់ចំពោះទំនិញ ឬសេវាដូចគ្នានៅក្នុងប្រទេសមួយ ឬច្រើន ដែលជាហត្ថលេខីនៃអនុសញ្ញាអន្តរជាតិ (អនុសញ្ញាទីក្រុងប៉ារីស) ក្នុងរយៈពេល០៦ខែចុងក្រោយ នោះអ្នកដាក់ពាក្យសុំអាចប្រកាសសិទ្ធិអាទិភាពរបស់ខ្លួនផ្តើមចេញពីកាលបរិច្ឆេទចុះបញ្ជីមុន ចំពោះការដាក់ពាក្យសុំចុះបញ្ជីរបស់ខ្លួនក្នុងប្រទេសកម្ពុជា។ ការប្រកាសអាទិភាព ត្រូវធ្វើឡើងនៅពេលដែលការដាក់ពាក្យសុំចុះបញ្ជីតែមួយក្នុងប្រទេសកម្ពុជា ។ ដើម្បីប្រកាសកាលបរិច្ឆេទអាទិភាព តាមអនុសញ្ញាអន្តរជាតិ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកត្រូវផ្តល់នូវការបរិយាយលំអិត នៅពេលដាក់ពាក្យសុំចុះបញ្ជីដូចតទៅ ៖

- ឈ្មោះប្រទេសដែលបានដាក់ពាក្យសុំចុះបញ្ជីរួចហើយ
- កាលបរិច្ឆេទនៃការដាក់ពាក្យសុំចុះបញ្ជីដែលអនុវត្តតាមអនុសញ្ញាអន្តរជាតិ និងលេខរៀងនៃការដាក់ពាក្យសុំចុះបញ្ជី ដែលអនុវត្តអនុសញ្ញាអន្តរជាតិ (ប្រសិនបើពុំអាចរកបាននៅពេលដាក់ពាក្យសុំចុះបញ្ជី)

លេខរៀងនេះ ត្រូវផ្តល់ឱ្យនៅក្នុងរយៈពេលបីខែបន្ទាប់ពីការដាក់ពាក្យសុំចុះបញ្ជីម៉ាក ឬអាចមុនពេលធ្វើការចុះបញ្ជីម៉ាក ដែលក្នុងករណីនេះគេអាចជ្រើសរើសពេលវេលាណាមួយ ដែលមក

---

[១៧] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, នស/រកម/០២០២/០០៦, ០៧.កុម្ភៈ.២០០២, មាត្រា៦។

ដល់មុនគេបាន[១៨] ។ ក្នុងករណីនេះបើមិនមានការបំពេញលក្ខខណ្ឌដែលច្បាប់បានកំណត់ទេនោះ មិនមានការប្រកាសនូវសិទ្ធិអាទិភាពទេ និងមិនមានការចុះបញ្ជីមុនឡើយ ។ តែបើសិនមានលក្ខខណ្ឌណាមួយនៃការប្រកាសសិទ្ធិអាទិភាពមិនបានបំពេញត្រឹមត្រូវ អ្នកដាក់ពាក្យសុំដល់មន្ត្រីអ្នកកាន់កាប់បញ្ជីឱ្យផ្តល់អាទិភាពនោះ នឹងកែតម្រូវនូវលក្ខខណ្ឌមិនឱ្យលើសពីរយៈពេល ០៣ខែឡើយ តែអាចពន្យាបានក្នុងករណីបញ្ហាណាមួយមានភស្តុតាងគ្រប់គ្រាន់ សមហេតុផលអាចទទួលយកបាន[១៩] ។

ឧទាហរណ៍ ៖ លោក សុខ បានដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកនៅប្រទេសថៃដែលកាលបរិច្ឆេទលើកទីមួយថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩ ហើយគាត់បានដាក់ពាក្យស្នើសុំអាទិភាពមកកាន់ប្រទេសកម្ពុជា ហើយកាលបរិច្ឆេទនៃសិទ្ធិអាទិភាពថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ កាលបរិច្ឆេទដាក់ពាក្យនៅប្រទេសកម្ពុជាថ្ងៃទី២០ ខែមិនា ឆ្នាំ២០១០ ក្នុងករណីនេះមន្ត្រីកាន់កាប់បញ្ជីគឺយកថ្ងៃដែលដាក់ពាក្យលើកទី០១ជាថ្ងៃចុះបញ្ជីម៉ាក ។

***គួរបញ្ជាក់ផងដែរថា៖ អនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់លេខ ៦៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៦ បានទទួលស្គាល់ "ភ្នាក់ងារតំណាង" ស្របជាមួយនឹងប្រកាសស្តីពីការទទួលស្គាល់អ្នកតំណាងស្របច្បាប់លេខ ២៥៨ ពណចបព.ប្រក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧*** បញ្ជាក់ឱ្យដឹងថា អ្នកមានសិទ្ធិសុំចុះបញ្ជីម៉ាកគឺច្បាប់ប្រគល់សិទ្ធិឱ្យទៅម្ចាស់ម៉ាកជាចម្បងម្នាក់គត់ សម្រាប់ដាក់ពាក្យសុំចុះបញ្ជី ក៏ប៉ុន្តែក្នុងករណីដែលលំនៅដ្ឋានអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មចម្បងរបស់អ្នកស្នើសុំចុះបញ្ជី ពោលគឺក្រុមហ៊ុនជាអាទិ៍ស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជា អ្នកស្នើសុំនោះត្រូវមានតំណាងជាភ្នាក់ងារ ដែលមានទីលំនៅ និងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា[២០] ហើយសម្រាប់អ្នកតំណាងជាភ្នាក់ងារក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកនៅព្រះរាជាណាចក្រកម្ពុជា ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចមានចែងនៅក្នុងប្រកាសស្តីពីការទទួលស្គាល់អ្នកតំណាងស្របច្បាប់លេខ ២៥៨ ពណចបព.ប្រក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧[២១] ។ ក្នុងករណីមានការប្តូរម្ចាស់កម្មសិទ្ធិ ឬផ្ទេរសិទ្ធិតម្រូវឱ្យមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាមុន[២២] ។

---

[១៨] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពំប្រកួតប្រជែងមិនស្មោះត្រង់២០០២ និងមាត្រា១៣អនុក្រឹត្យឆ្នាំ២០០៦ មាត្រា៦។

[១៩] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០៦ មាត្រា១៣។

[២០] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, នស/រកម/០២០២/០០៦, ០៧.កុម្ភៈ.២០០២, មាត្រា៥៨ ។

[២១] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, នស/រកម/០២០២/០០៦, ០៧.កុម្ភៈ.២០០២, មាត្រា៥៩។

[២២] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, នស/រកម/០២០២/០០៦, ០៧.កុម្ភៈ.២០០២, មាត្រា៤៩។

**លិខិតប្រគល់សិទ្ធិ** គឺជាលិខិតមួយប្រភេទដែលអ្នកស្នើសុំប្រគល់ ឬផ្ទេរសិទ្ធិជូនភ្នាក់ងារជាតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជី ពោលគឺចាត់តាំងឱ្យភ្នាក់ងារជាតំណាងធ្វើការដាក់ពាក្យដោយភ្ជាប់ជាមួយនឹងពាក្យស្នើសុំចុះបញ្ជី ឬត្រូវប្រគល់សិទ្ធិនោះ ទៅឱ្យមន្ត្រីកាន់កាប់បញ្ជី នៅក្នុងរយៈពេល២ខែ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជី ។ ប្រសិនបើក្នុងករណីដែលការប្រគល់សិទ្ធិនេះ មិនត្រូវបានធ្វើឡើង និងមិនសមស្របតាមបញ្ញត្តិមាត្រា ៥៨ និងមាត្រា ៥៩ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់ ព្រមជាមួយនឹងបញ្ញត្តិមាត្រា ២៨ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់ នោះចំណាត់ការតាមនីតិវិធីក្នុងការចុះបញ្ជីមិនត្រូវបានធ្វើឡើយ[២៣] ។ អ្នកតំណាងជាភ្នាក់ងារទាំងនោះអាចជាអ្នកភ្នាក់ងារតំណាង ឬមេធាវី ឬសារការីសាធារណៈជាដើម ។

***អាសយដ្ឋាន ឬទីតាំងអាជីវកម្ម***

ការចុះបញ្ជីម៉ាក អាសយដ្ឋានសម្រាប់ទាក់ទងវាមានសារៈសំខាន់ ព្រោះវាជាប្រយោជន៍ដល់អ្នកស្នើសុំងាយស្រួលប្រាស្រ័យទាក់ទងជាមួយនឹងមន្ត្រីកាប់កាន់បញ្ជី ពោលគឺអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកចាំបាច់ត្រូវផ្តល់មកឱ្យមន្ត្រីកាន់កាប់បញ្ជី នូវអាសយដ្ឋានសម្រាប់ទាក់ទងក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រើប្រាស់ក្នុងគោលបំណងនៃការដាក់ពាក្យ[២៤] ។

អាសយដ្ឋានសម្រាប់ទាក់ទងនេះ វាអាចមាននៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬក្រៅព្រះរាជាណាចក្រកម្ពុជា ។ ជនបរទេសដែលមកសុំចុះបញ្ជីម៉ាក គឺត្រូវផ្តល់អាសយដ្ឋានសម្រាប់ទាក់ទងក្នុងព្រះរាជាណាចក្រកម្ពុជា ដល់មន្ត្រីកាន់កាប់បញ្ជី ។ម្យ៉ាងទៀត ករណីដែលអាសយដ្ឋានអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មរបស់អ្នកដាក់ពាក្យសុំ ស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជាវិញ តើអ្នកដាក់ពាក្យសុំធ្វើដូចម្តេច?

ដូចដែលបានលើកឡើងខាងលើ ទាក់ទងនឹងអាសយដ្ឋានសម្រាប់ទាក់ទងនេះ *"បទបញ្ញត្តិមាត្រា៥៨ នៃច្បាប់ស្តីពីការចុះបញ្ជីម៉ាក ពាណិជ្ជនាម និងអំពើនៃប្រកួតប្រជែងមិនស្មោះត្រង់ ព្រមទាំងមាត្រា៧ នៃអនុក្រឹត្យស្តីពីអនុវត្តច្បាប់ស្តីពីការចុះបញ្ជីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦"* បញ្ជាក់ថា "ទីលំនៅ ឬទីតាំងប្រកបអាជីវកម្ម ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ពីអាសយដ្ឋានណាឱ្យពិតប្រាកដ ក្នុងករណីមានលំនៅដ្ឋានអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មក្រៅព្រះរាជាណាចក្រកម្ពុជា អ្នកដាក់ពាក្យសុំអាចយកអាសយដ្ឋានរបស់ភ្នាក់ងារជាតំណាង ឬអ្នកតំណាងស្របច្បាប់ ឬមេធាវី ឬសារការីសាធារណៈ មកធ្វើការទាក់ទងជំនួសវិញ" ។

---

[២៣] អនុក្រឹត្យស្តីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦ មាត្រា៧។
[២៤] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២ មាត្រា២៥។

## ១.៣ លក្ខខណ្ឌម៉ាកដែលមិនទទួលបានការចុះបញ្ជី

បើទោះបីជាច្បាប់ស្តីពីម៉ាកបានផ្តល់អត្ថិភាព សេរីភាពដល់ម្ចាស់ម៉ាកក្នុងការចុះបញ្ជីក៏ដោយ ប៉ុន្តែលក្ខខណ្ឌមួយចំនួន ក្នុងការចុះបញ្ជីហាមឃាត់មិនឱ្យម៉ាកទំនិញមួយចំនួនចុះបញ្ជីផងដែរ ។ ជាទូទៅ ក្នុងការចុះបញ្ជី និងមិនអនុញ្ញាត្ត ប្រសិនបើម៉ាកទាំងឡាយនោះមិនអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញរបស់សហគ្រាសមួយទៅនឹងសហគ្រាសមួយទៀត ប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីជាតិ ។

ម៉ាកដែលមិនអាចចុះបញ្ជីបានមានដូចតទៅ[២៥]៖

ក. ម៉ាកដែលមិនអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវារបស់សហគ្រាសមួយទៅនឹងសហគ្រាសមួយផ្សេងទៀត។

ខ. ម៉ាកដែលបណ្តាលឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីល្អរបស់ជាតិ។

គ. ម៉ាកដែលអាចនាំឱ្យសាធារណជន ឬមជ្ឈដ្ឋាន ពាណិជ្ជកម្មភ័ន្តច្រឡំទៅនឹងប្រភពភូមិសាស្ត្រនៃទំនិញ សេវាពាក់ព័ន្ធ ធាតុដើម លក្ខណៈខាងក្រៅរបស់ទំនិញ ឬសេវានោះ។

ឃ. ម៉ាកដែលដូចគ្នា និង/ឬត្រាប់តាម ឬមានចំណុចណាមួយដូច សញ្ញាជាតិ ទង់ជាតិ និងនិមិត្តរូបផ្សេងៗ ឈ្មោះ ឬឈ្មោះសង្ខេប ឬអក្សរកាត់នៃឈ្មោះ ឬសញ្ញា ឬត្រាជាផ្លូវការដែលអនុម័តដោយរដ្ឋណាមួយ អង្គការអន្តររដ្ឋាភិបាល ឬអង្គការដែលបង្កើតឡើងដោយអនុសញ្ញាអន្តរជាតិមួយ លើកលែងមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋនោះ ឬអង្គការនោះ។

ង. ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែល ដែលនាំឱ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បីក្នុងព្រះរាជាណាចក្រកម្ពុជា ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះ សម្រាប់ទំនិញ ឬសេវាដូចគ្នា ឬប្រហាក់ប្រហែលគ្នានៃសហគ្រាសមួយទៀត។

ច. ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែល ដែលនាំឱ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បី ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះ ហើយបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ទំនិញ ឬសេវាដែលមិនដូចគ្នា ឬមិនប្រហាក់ប្រហែលគ្នា ដោយការប្រើប្រាស់ម៉ាកនោះធ្វើឱ្យខូចប្រយោជន៍របស់ម្ចាស់នៃម៉ាកល្បី។

[២៥] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, នស/រកម/០២០២/០០៦, ០៧.កុម្ភៈ.២០០២, មាត្រា៤។

ឆ. ម៉ាកដែលដូចគ្នា ឬស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងម៉ាក ដែលជាកម្មសិទ្ធិរបស់ម្ចាស់ផ្សេងដែលបានចុះបញ្ជីរួចហើយ ឬបានដាក់ពាក្យស្នើសុំចុះបញ្ជីមុន និង/ឬបានទទួលអាទិភាពចុះបញ្ជីមុន នៅឯបរទេស ចំពោះទំនិញ ឬសេវាដូចគ្នា ឬទំនិញ ឬសេវា ដែលពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ។

## ១.៤ អានុភាពក្នុងការចុះបញ្ជីម៉ាក និងការបញ្ចប់សិទ្ធិលើម៉ាក

អានុភាពរបស់ម៉ាកក្រោយពីចុះបញ្ជីហើយ អ្នកដទៃយកប្រើបាន លុះត្រាតែទទួលបានការអនុញ្ញាតពីម្ចាស់ដើម ។ ម្ចាស់ដើមមានសិទ្ធិប្តឹងទៅតុលាការ លើជនទាំងឡាយណាដែលប្រើប្រាស់ម៉ាករបស់ខ្លួនដោយគ្មានការអនុញ្ញាត ។ មួយវិញទៀត ម៉ាកដែលបានចុះបញ្ជីរួចហើយ ហើយមានអ្នកដទៃប្រើម៉ាកមានលក្ខណៈប្រហាក់ប្រហែល ដែលនាំមកការច្រឡំ ម្ចាស់ម៉ាកអាចប្តឹងទៅតុលាការបាន ។

ម៉ាកដែលបានចុះបញ្ជីហើយមានសុពលភាព១០ឆ្នាំ គិតពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំចុះបញ្ជី ។ ការចុះបញ្ជីនេះអាចធ្វើឡើងសារជាថ្មីសម្រាប់រយៈពេល១០ឆ្នាំម្តង ជាបន្តបន្ទាប់ក្នុងលក្ខខណ្ឌម្ចាស់ដើមបង់អាករចុះបញ្ជីជាថ្មីតាមការកំណត់ ។ ពាក្យស្នើសុំចុះបញ្ជីជាថ្មីចំពោះម៉ាកដែលបានចុះបញ្ជីរួចហើយ មុនច្បាប់នេះចូលជាធរមាន អ្នកស្នើសុំត្រូវបញ្ជាក់ឱ្យបានច្បាស់នូវប្រភេទទំនិញ ឬសេវាដោយផ្អែកតាមចំណាត់ថ្នាក់អន្តរជាតិ ។ ការអនុគ្រោះចំពោះការយឺតយ៉ាវក្នុងការចុះបញ្ជីជាថ្មី ត្រូវបានអនុញ្ញាតត្រឹមរយៈពេល៦ខែ[២៦] ។

ការលុបចោលម៉ាកគឺជាការបញ្ចប់សិទ្ធិលើម៉ាក ។ ការលុបចោលម៉ាកក្នុងលក្ខខណ្ឌដូចជាៈ (១)លុបចោលម៉ាកដែលបានផុតសុពលភាព ដោយម្ចាស់ម៉ាកមិនបានដាក់ពាក្យចុះបញ្ជីសារជាថ្មី ។ (២)លុបម៉ាកដែលចុះបញ្ជីហើយ តាមការស្នើសុំរបស់ម្ចាស់ម៉ាក ដែលម្ចាស់ម៉ាកលែងមានអាសយដ្ឋាននៅក្នុងកម្ពុជា ដែលមិនអាចទាក់ទងបាន។ (៣)លុបម៉ាកចុះបញ្ជីហើយក្នុងរយៈពេល៩០ថ្ងៃ ដែលម្ចាស់ម៉ាកមិនគោរពដោយផ្តល់ឯកសារគាំទ្រតាមការកំណត់។ (៤)លុបម៉ាកចុះបញ្ជីហើយ បើកាលណាមានភស្តុតាងបញ្ជាក់ថា ម្ចាស់ម៉ាកដែលបានចុះបញ្ជី មិនមែនជាម្ចាស់ម៉ាកស្របច្បាប់ ។ (៥) លុបម៉ាកចុះបញ្ជីហើយ កាលណារកឃើញថា ម៉ាកនោះដូច ឬប្រហាក់ប្រហែលម៉ាកល្បី កម្មសិទ្ធិរបស់ភាគីទីបី ។ (៦)ម្ចាស់ម៉ាកខ្លួនឯងផ្ទាល់អាចស្នើសុំលុបម៉ាកនោះចេញពីបញ្ជី ។

[២៦] សន្ធិសញ្ញាអន្តរជាតិស្តីអំពីកម្មសិទ្ធិឧស្សាហកម្ម (ម៉ាក ពាណិជ្ជនាម) ក្នុងនាមកម្ពុជាជាប្រទេសហត្ថលេខីមួយនៃសន្ធិសញ្ញានោះដែលត្រូវយកមកអនុវត្តន៍ជាមួយច្បាប់កម្ពុជា» មាត្រា៦០ និង ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, នស/រកម/០២០២/០០៦, ០៧.កុម្ភៈ.២០០២ មាត្រា១២។

# ជំពូក ២

# នីតិវិធីរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក

## ២.១ រចនាសម្ព័ន្ធនាយកដ្ឋានកម្មសិទ្ធិបញ្ញា

ការត្រួតពិនិត្យ និងចុះបញ្ជីម៉ាក ជាសិទ្ធិរបស់មន្ត្រីកាន់កាប់បញ្ជីម៉ាក នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។ នាយកដ្ឋានកម្មសិទ្ធិបញ្ញាត្រូវបានបង្កើតឡើង តាមអនុក្រឹត្យនៃរាជរដ្ឋាភិបាលកម្ពុជាលេខ ៥៤ នៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧[២៧] ។

ពេលគឺបច្ចុប្បន្នក្រសួងពាណិជ្ជកម្ម មាននាយកដ្ឋានចំណុះហៅថា **"នាយកដ្ឋានកម្មសិទ្ធិបញ្ញា"** ដែលដឹកនាំដោយលោក **អប់ រ៉ាឌី** ជាប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញាហើយនាយកដ្ឋាននេះមានការិយាល័យចំណុះចំនួន ០៦ ដែលមានការិយាល័យមួយឈ្មោះថា ការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្ម ដែលមានតួនាទីទទួលបន្ទុកក្នុងការចុះបញ្ជីម៉ាក ។ ដោយយោងតាមមាត្រា ៤ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា បានបញ្ញត្តិអំពីការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្ម ទទួលបន្ទុកដូចជាៈ (១)សហការជាមួយមន្ទីរ ខេត្ត ក្រុងក្នុងការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក និងម៉ាកល្បីពីសំណាក់ម្ចាស់ម៉ាកដែលមានលំនៅដ្ឋានអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មសំខាន់ក្នុងប្រទេសកម្ពុជា (២)ធ្វើការស្រាវជ្រាវ និងវាយតម្លៃម៉ាកល្បីៗ ដើម្បីកំណត់ថាមានការរំលោភបំពានម៉ាក ឬគ្មាន (៣)ត្រួតពិនិត្យខ្លឹមសារម៉ាក (៤)ទទួលនិងដោះស្រាយរាល់បណ្តឹងតវ៉ា និងបណ្តឹងជំទាស់មុនពេលម៉ាកត្រូវបានចុះបញ្ជី (៥)ចុះបញ្ជីម៉ាកនិងផ្តល់វិញ្ញាបនបត្រម៉ាក (៦)កត់ត្រា ប្តូរឈ្មោះ ប្តូរអាសយដ្ឋាន ការរួមបញ្ចូលគ្នានៃម្ចាស់ម៉ាកការផ្ទេរសិទ្ធិគ្រប់គ្រងម៉ាក និងកត់ត្រា ការផ្តល់អាជ្ញាប័ណ្ណមុនពេលម៉ាកត្រូវបានចុះបញ្ជី ។

បន្ទាប់ពីការិយាល័យចុះបញ្ជីម៉ាកទទួលពាក្យស្នើសុំចុះបញ្ជីម៉ាករួចមក មន្ត្រីកាន់កាប់បញ្ជីត្រូវតែធ្វើការត្រួតពិនិត្យលើពាក្យស្នើសុំ និងឯកសារពិនិត្យមើលថា តើម៉ាកដែលស្នើសុំចុះបញ្ជីនោះមានភាពស្របច្បាប់ដែរឬទេ? **(ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញានេះជាមន្ត្រីកាន់កាប់បញ្ជីម៉ាក)**

នាយកដ្ឋានកម្មសិទ្ធិបញ្ញា ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម មានតួនាទី និងភារកិច្ចដូចជា[២៨]ៈ (១)ជាលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា (២)សហការ និងជំរុញក្រសួងពាក់ព័ន្ធចងក្រង និងអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាស្របតាមការសន្យាការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា (៣)សហការជាមួយក្រសួងពាក់ព័ន្ធទទួលនឹងប្រើប្រាស់ជំនួយបច្ចេកទេស ពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញាពី

[២៧] http://cambodiaip.gov.kh/TemplateTwo.aspx?parentId=2&menuid=39&childMasterMenuId=29.

[២៨] http://cambodiaip.gov.kh/TemplateTwo.aspx?parentId=2&menuid=61&childMasterMenuId=29.

អង្គការអន្តរជាតិ និងប្រទេសនានា (៤)ទទួលបន្ទុកជាចំណុចកណ្តាល ការសម្របសម្រួលកិច្ចសហប្រតិបត្តិការទ្វេភាគី ឬពហុភាគីលើវិស័យកម្មសិទ្ធិបញ្ញា ជាមួយបណ្តាប្រទេស និងអង្គការអន្តរជាតិផ្សេងៗ (៥)សហការផ្សព្វផ្សាយច្បាប់ បទប្បញ្ញត្តិនានា និងចំណេះដឹងផ្នែកកម្មសិទ្ធិបញ្ញាទៅដល់មហាជន ស្ថាប័ន អប់រំ និងមន្ត្រីអនុវត្តច្បាប់ ។

ទទួលបន្ទុក និងសហការរៀបចំច្បាប់ និងបទប្បញ្ញត្តិ ទាក់ទងនឹងកម្មសិទ្ធិបញ្ញាដូចជាៈ (១)ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ (២)ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ (៣)កិច្ចការពារពត៌មានសម្ងាត់ពាណិជ្ជកម្ម (៤)ការផ្ទេរអាជ្ញាប័ណ្ណ និងសិទ្ធិធ្វើអាជីវកម្ម (៥)កម្មសិទ្ធិបញ្ញាផ្សេងៗទៀត ជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម (៦)ធ្វើការចុះបញ្ជីម៉ាក និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ព្រមទាំងកត់ត្រាការផ្តល់អាជ្ញាប័ណ្ណ និងការផ្តល់សិទ្ធិធ្វើអាជីវកម្មម៉ាក (៧)ចេញលិខិតទទួលស្គាល់សិទ្ធិផ្តាច់មុខម៉ាកផលិតផលស្របតាមច្បាប់ និងតាមសំណូមពររបស់ម្ចាស់ម៉ាកដោយស្របច្បាប់ (៨)សហការជាមួយមន្ទីរពាណិជ្ជកម្មខេត្ត ក្រុង ក្នុងការទទួលពាក្យចុះបញ្ជី និងដោះស្រាយវិវាទ អំពីម៉ាក និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ (៩)ដោះស្រាយវិវាទនានា ទាក់ទងនឹងកម្មសិទ្ធិបញ្ញា ជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម (១០)សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នតុលាការ ដើម្បីបញ្ឈប់ការរំលោភកម្មសិទ្ធិបញ្ញា (១១)បង្កើត និងគ្រប់គ្រងគេហទំព័រ ដើម្បីផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិនានា ព្រមទាំងទិន្នន័យកម្មសិទ្ធិបញ្ញាដែលបានចុះបញ្ជីរួច (១២)ចូលរួមសិក្សាស្រាវជ្រាវកិច្ចព្រមព្រៀង និងអនុសញ្ញាអន្តរជាតិនានា ទាក់ទងនឹងកម្មសិទ្ធិបញ្ញា និងធ្វើការពិចារណាអំពីប្រយោជន៍ជាតិ ក្នុងការចូលរួមជាសមាជិក នៃកិច្ចព្រមព្រៀង ឬអនុសញ្ញាទាំងនោះ (១៣)ជំរុញការធ្វើពាណិជ្ជកម្មកម្មសិទ្ធិបញ្ញា និងការវាយតម្លៃទ្រព្យសម្បត្តិកម្មសិទ្ធិបញ្ញា ដែលជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម (១៤)អនុវត្តរាល់ភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

## ២.២ នីតិវិធីរដ្ឋបាល

### ២.២.១ ការវិនិច្ឆ័យម៉ាក

#### ក. ការវិនិច្ឆ័យចំពោះម៉ាកធម្មតា

ម៉ាកធម្មតា ជាម៉ាកដែលមានលក្ខណៈធម្មតាមដូចជា ឈ្មោះ(ឈ្មោះពិត ឬឈ្មោះសិប្បនិម្មិត) អក្សរ លេខ រូបភាព និមិត្តសញ្ញា ឡូហ្គោ ពាក្យ បង្គុំនៃពណ៌ ឬបង្គុំនៃសញ្ញាជាដើម[២៩] ។ ដូចនេះយើងនឹងធ្វើការវិនិច្ឆ័យចំពោះម៉ាកធម្មតាដូចខាងក្រោមនេះៈ

[២៩] នី វិចិត្រ, *នីតិកម្មសិទ្ធិបញ្ញា (ភ្នំពេញៈ ក្រុមហ៊ុនមេធាវី អេចប៊ីអេស ២០១៣)*, ទំព័រ១៨៥។

*ក.១ ការត្រួតពិនិត្យបឋម*

ចំពោះការត្រួតពិនិត្យបឋម រាល់សំណុំឯកសារដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវតែជាច្បាប់ដើម និងបំពេញលក្ខខណ្ឌ ៥ចំណុចដូចខាងក្រោម៖ (១)ឈ្មោះរបស់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក (២)អាសយដ្ឋានទំនាក់ទំនង (៣)គំរូម៉ាក ដែលស្នើសុំចុះបញ្ជី (៤)យថាប្រភេទរបស់ទំនិញ ឬសេវាដែលស្នើសុំចុះបញ្ជីក្នុងចំណាត់ថ្នាក់នីមួយៗ (៥)កម្រៃនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកដែលតម្រូវសម្រាប់ ចំណាត់ថ្នាក់នីមួយៗនៃទំនិញ ឬសេវា ដែលសុំចុះបញ្ជីម៉ាក ។

ក្រសួងពាណិជ្ជកម្មនឹងចេញលេខ និងកាលបរិច្ឆេទដាក់ពាក្យសុំចុះបញ្ជីម៉ាកជូនក្រោយពេលអ្នកស្នើសុំបានបំពេញគ្រប់លក្ខខណ្ឌខាងលើនេះ ។

លិខិតប្រគល់សិទ្ធិ ដែលចាត់តាំងភ្នាក់ងារតំណាងមួយឱ្យធ្វើការដាក់ពាក្យអាចភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជី ឬត្រូវប្រគល់លិខិតសិទ្ធិនោះទៅឱ្យមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល០២ (ពីរ) ខែគិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យ ។ ប្រសិនបើមានការប្រគល់សិទ្ធិ មិនត្រូវបានធ្វើឡើង និងធ្វើឡើងមិនសមស្របតាមមាត្រាច្បាប់នោះ ចំណាត់ការតាមនីតិវិធីណាមួយក្នុងការចុះបញ្ជីនឹងមិនត្រូវធ្វើឡើងឡើយ[៣០] ។

*ក.២ លក្ខខណ្ឌវិនិច្ឆ័យ ៥៥ចំណុចនៃការត្រួតពិនិត្យម៉ាកលម្អិត*

កង្វះភាពញែកដាច់ដូចជា៖ (១)ពណ៌តែមួយ (២)អក្សរ ឬលេខតែមួយ (៣)គំនូរបែបប្រពៃណី ឬគំនូរគំរូ (៤)សញ្ញាស្មុគស្មាញ ឬពិបាកយល់ (៥)ឃ្លាទូទៅ ឬពាក្យស្លោក (៦)ទម្រង់រូបរាងផលិតផល (៧)សញ្ញាទូទៅ (៨)រូបភាពធរណីមាត្រទូទៅ៖

លក្ខណៈពិពណ៌នាមានដូចជា៖ (១)ប្រភេទ/ធាតុដើមនៃទំនិញ ឬសេវាកម្ម (២)គុណភាពទំនិញ ឬសេវកម្ម (៣)បរិមាណ ឬសេវាកម្ម (៤)គោលបំណងទំនិញ ឬសេវាកម្ម (៥)តម្លៃទំនិញ ឬសេវាកម្ម (៦)ពេលវេលានៃការផលិតទំនិញ ឬសេវាកម្ម (៧)ប្រភពដើមភូមិសាស្ត្រនៃទំនិញ ឬសេវាកម្ម (៨)ចរិតលក្ខណៈទំនិញ ឬសេវាកម្ម (៩)ការប្រើប្រាស់ ឬអ្នកប្រើប្រាស់ (១០)មុខងារនៃទំនិញ ឬសេវាកម្ម (១១)បង្កំពាក្យពិពណ៌នា (១២)ការពិចារណាបន្ថែម (សូរសព្ទសមមូល ការប្រកបពាក្យខុស ពាក្យកម្ចីពីបរទេស ពាក្យMister ឬ លោកវេជ្ជបណ្ឌិត Dr. ពាក្យស័ព្ទថ្មី ម៉ាកផ្ដើមដោយអក្សរ E ឬ I ឈ្មោះគេហទំព័រម៉ាកផ្ដើមពាក្យ Smart........) (១៣)ផ្សេងៗទៀត (នាមត្រកូល ឈ្មោះទូទៅ ចរិតលក្ខណៈ ការប្រើប្រាស់/អ្នកប្រើប្រាស់គ្រឿងផ្សំ មុខងារ លក្ខណៈពិសេស) ។

*ក.៣ លក្ខណៈទូទៅ*គឺ (១)ម៉ាកដូចនឹងទំនិញ ឬសេវកម្ម (២)ឈ្មោះប្រភេទរុក្ខជាតិ ។

[៣០] ប្រកាសស្ដីពីលក្ខខណ្ឌនៃពាក្យស្នើសុំចុះម៉ាកថ្មីលេខ ០០១៦ ព.ណកសប, ០៥.មករា.២០១៥ របស់ក្រសួងពាណិជ្ជកម្ម។

*ក.៤ ផ្ទុយនឹងសណ្តាប់ធ្នាប់ ឬសីលធម៌ ឬប្រពៃណីល្អ* (១)ហាមឃាត់ដោយគោលនយោបាយរបស់រដ្ឋាភិបាល (២)ពាក់ព័ន្ធនឹងបញ្ហាសាសនា (៣)ពាក់ព័ន្ធនឹងពូជសាសន៍ ភេទ ជំនឿ ឧក្រិដ្ឋកម្ម សុជីវធម៌ ឬន័យលាក់បាំងអាក្រក់ ។

*ក.៥ ម៉ាកដែលនាំឱ្យភាន់ច្រឡំទៅនឹងភូមិសាស្ត្រនៃទំនិញ ឬសេវាពាក់ព័ន្ធ ឬធាតុដើម ឬលក្ខណៈខាងក្រៅរបស់ទំនិញ ឬសេវានោះ៖* (១)ប្រភពភូមិសាស្ត្រ (២)ធាតុដើមទំនិញ ឬសេវា (៣)ក្រុមអ្នកទិញ (៤)ប្រភេទប្រតិបត្តិការណ៍ (៥)សមាសភាពផ្សំ (៦)បំណងប្រើប្រាស់ ឬគោលដៅប្រើប្រាស់ (៧)គុណភាព (៨)បរិមាណ (៩)សញ្ញាដែលនាំឱ្យច្រឡំថាទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ចណាមួយ (១០)ឈ្មោះជនល្បី (១១)ឈ្មោះធាតុផ្សំទូទៅរបស់ឱសថនៅក្នុង (INN) របស់អង្គការសុខភាពពិភពលោក WHO ។

*ក.៦ ម៉ាកដូចគ្នា ឬត្រាប់តាម ឬមានចំណុចណាមួយដូចជា សញ្ញាជាតិ ទង់ជាតិ និមិត្តរូបផ្សេងៗ ឈ្មោះ ឬឈ្មោះសង្ខេប ឬអក្សរកាត់នៃឈ្មោះ ឬសញ្ញា ឬត្រាផ្លូវការ ដែលអនុម័តដោយរដ្ឋណាមួយ អង្គការអន្តររដ្ឋាភិបាល ឬអង្គការដែលបានបង្កើតដោយអនុសញ្ញាអន្តរជាតិមួយមានដូចជា៖* (១)ឈ្មោះ និងអក្សរកាត់របស់ប្រទេស (២)សញ្ញាជាតិរបស់ជាតិនីមួយៗ (បណ្តាប្រទេស និងដែនដីទាំងអស់នៅក្នុងពិភពលោក) (៣)ទង់ជាតិរបស់រដ្ឋនីមួយៗ (បណ្តាប្រទេស និងដែនដីទាំងអស់នៅក្នុងពិភពលោក) (៤)និមិត្តរូបរបស់រដ្ឋនីមួយៗ (បណ្តាប្រទេស និងរដ្ឋទាំងអស់នៅក្នុងពិភពលោក) (៥)សញ្ញា និងត្រាផ្លូវការដែលអនុម័តដោយរដ្ឋនីមួយៗ (បណ្តាប្រទេស និងរដ្ឋទាំងអស់នៅក្នុងពិភពលោក) (៦)ឈ្មោះ និងអក្សរកាត់របស់អង្គការអន្តរជាតិ ឬអន្តររដ្ឋាភិបាល (៧)សញ្ញាជាតិនៃអង្គការអន្តរជាតិ ឬអន្តររដ្ឋាភិបាល (៨)ទង់ជាតិអង្គការអន្តរជាតិ ឬអន្តររដ្ឋាភិបាល (៩)និមិត្តរូបអង្គការអន្តរជាតិ/អន្តររដ្ឋាភិបាល (១០)សញ្ញា និងនិមិត្តរូបផ្សេងៗ ដែលបានការពារដោយអនុសញ្ញាទាំងឡាយ និងអនុសញ្ញាទីក្រុងប៉ារីស ដើម្បីការពារកម្មសិទ្ធិឧស្សាហកម្ម ។

*ក.៧ ម៉ាកល្បី៖* (១)សញ្ញាដូចគ្នា និងទំនិញ/សេវាកម្មស្រដៀងគ្នា (២)សញ្ញាស្រដៀង និងទំនិញ/សេវាកម្មដូចគ្នា (៣)សញ្ញាស្រដៀង និងទំនិញ/សេវាកម្មស្រដៀងគ្នា (៤)សញ្ញាដូចគ្នា និងទំនិញ/សេវាកម្មមិនស្រដៀងគ្នា (៥)ដូចផ្នែកណាមួយជាលក្ខណៈពិសេសរបស់ម៉ាក និងទំនិញ/សេវាកម្មស្រដៀងគ្នា (៦)ស្ទើរតែដូចទាំងស្រុងជាមួយនឹងម៉ាក និងទំនិញ/សេវាកម្មមិនស្រដៀងគ្នា (៧)ម៉ាកស្រដៀងគ្នា និងទំនិញ/សេវាកម្មដូចគ្នា (៨)ម៉ាកស្រដៀងគ្នា និងទំនិញ/សេវាកម្មពាក់ព័ន្ធយ៉ាងជិតស្និត (៩)ការបកប្រែ/អត្ថន័យ (១០)ការសរសេរតាមសំឡេងអាន (១១)អនុសញ្ញាទីក្រុងប៉ារីសសម្រាប់ការការពារសិទ្ធិឧស្សាហកម្ម (១២)អនុសាសន៍រួមស្តីពីបទប្បញ្ញត្តិកិច្ចការពារម៉ាកល្បីរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ។

*ក.៨ ម៉ាកដូចគ្នា ឬស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងម៉ាក ដែលជាកម្មសិទ្ធិរបស់ម្ចាស់ផ្សេងដែលបានចុះបញ្ជីរួចហើយ ឬបានដាក់ពាក្យស្នើសុំចុះបញ្ជីមុន ឬបានទទួលអាទិភាពចុះបញ្ជីមុននៅឯបរទេសចំពោះទំនិញ ឬសេវាដូចគ្នា ឬទំនិញ ឬសេវាដែលពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ៖* (១) ដូចគ្នា ស្រដៀងគ្នាទៅម៉ាកចុះបញ្ជីមានទំនិញដូចសេវាដូចគ្នា (សំឡេង ពាក្យ រូបរាង រូបភាព) (២) ដូចគ្នា ស្រដៀងគ្នានឹងម៉ាកដាក់ពាក្យសុំចុះបញ្ជីមុនមានទំនិញ/សេវាដូចគ្នា (សំឡេង ពាក្យ រូបរាង រូបភាព) (៣)ស្ទើរតែដូចម៉ាកដែលជាការបោកបញ្ឆោត/បណ្តាលឱ្យមានការភ័ន្តច្រឡំទំនិញ/សេវាដូចគ្នា (សំឡេង ពាក្យ រូបរាង រូបភាព) (៤)ដូចគ្នា ស្ទើរតែដូចគ្នាទាំងស្រុងនឹងម៉ាកទៅនឹងសំឡេងអានរបស់ម៉ាកល្បី (៥)រូបរាងមើលឃើញ (៦)សំឡេង/សូរសព្ទ (៧)ប្រៀបធៀបទម្រង់ទាំងមូល (៨) លក្ខណៈពិសេសនៃម៉ាក ។

ជាទូទៅ ចំពោះម្ចាស់ម៉ាកដែលមានបំណងចង់ធ្វើការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួនត្រូវឆ្លងកាត់នីតិវិធីក្នុងការត្រួតពិនិត្យពីទម្រង់ ដូចដែលបានរៀបរាប់ខាងលើនេះដើម្បីចៀសវាងមានបញ្ហា ឬវិវាទ នៅពេលក្រោយ ។

**ខ. ការវិនិច្ឆ័យចំពោះពាណិជ្ជនាម**

នាម ឬសញ្ញាសម្គាល់ មិនអាចត្រូវបានប្រើប្រាស់ជាពាណិជ្ជនាមឡើយ ប្រសិនបើសារជាតិ ឬការប្រើប្រាស់នាម ឬសញ្ញាសម្គាល់ដែលបានកំណត់នោះ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌ និងជាពិសេសអាចមានការបំភ័ន្តដល់មជ្ឈដ្ឋានពាណិជ្ជកម្ម ឬសាធារណជន អំពីប្រភេទនៃសហគ្រាសដែលកំណត់ដោយនាមនោះ[៣១] ។

ការវិនិច្ឆ័យចំពោះពាណិជ្ជនាម មានលក្ខណៈខុសគ្នាទៅនឹងការធ្វើការវិនិច្ឆ័យម៉ាកធម្មតាព្រោះដោយហេតុថាពាណិជ្ជនាម ជានាម ឬសញ្ញាសម្គាល់របស់ក្រុមហ៊ុន ឬសហគ្រាសដូចនេះហើយ នីតិវិធីក្នុងការត្រួតពិនិត្យ និងវិនិច្ឆ័យមុនពេលចុះបញ្ជីមានលក្ខណៈដាច់ដោយឡែកពីគ្នាទៅនឹងម៉ាកធម្មតា ។ ដើម្បីធ្វើការចុះពាណិជ្ជនាមមួយតម្រូវមានឯកសារមួយចំនួនដូចជា បញ្ជីលក្ខន្តិកៈក្រុមហ៊ុន, បទបញ្ជាផ្ទៃក្នុង, អនុស្សរណៈនៃការយោគយល់គ្នា និងផ្សេងៗទៀត ។ ដូចនេះ ជាបឋមត្រូវទៅពិនិត្យឈ្មោះក្រុមហ៊ុនដែលមានបំណងចង់ដាក់ឈ្មោះជាមុនសិន ប្រសិនបើឈ្មោះដែលទំនេរត្រូវតែទៅសុំនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនិងទទួលការយល់ព្រមពីនាយកដ្ឋាននោះ ។

*ខ.១ ពិនិត្យអំពីភាពទំនេរនៃឈ្មោះក្រុមហ៊ុន*

ក្រសួងពាណិជ្ជកម្ម បានចេញនូវសេចក្តីប្រកាសលេខ ២៩៩ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ ដើម្បីអនុវត្តនីតិវិធីនៃការចុះបញ្ជីតាមរយៈប្រព័ន្ធអនឡាញជាមួយគេហទំព័រខាងក្រោម[៣២]៖

---

[៣១] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, នស/រកម/០២០២/០០៦, ០៧.កុម្ភៈ.២០០២, មាត្រា២០១

[៣២] https://www.businessregistration.moc.gov.kh/laws-and-regulations/

ក្រុមហ៊ុនដែលចុះបញ្ជីទាមទារឱ្យមានគណនេយ្យពាណិជ្ជកម្មមួយ ជាមួយគេហទំព័រនេះ ដូច្នេះគេអាចស្វែងរកឈ្មោះរបស់ក្រុមហ៊ុន និងកត់ត្រាទុកឈ្មោះក្រុមហ៊ុនដោយគ្រាន់តែបញ្ចូលនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ម្ចាស់ក្រុមហ៊ុនដែលនឹងត្រូវបង្កើតនោះជាការស្រេច ។ ដំណាក់កាលនេះគឺត្រូវការពេល ៧ថ្ងៃ ហើយត្រូវចំណាយ ១០ដុល្លារអាមេរិក ។ ការបង់ថ្លៃចុះឈ្មោះនេះ គឺត្រូវធ្វើឡើងដោយការបង់តាមអនឡាញដូចគ្នាតាមរយៈធនាគារពាណិជ្ជកម្មណាមួយ ដូចជា ធនាគារអេស៊ីលីដា និងធនាគារ FTB ជាដើម ។ ការពិនិត្យឈ្មោះក្រុមហ៊ុន មានភាពសំខាន់ណាស់សម្រាប់ម្ចាស់ក្រុមហ៊ុនដើម្បីចៀសវាងការប្រើប្រាស់ពាណិជ្ជនាមដែលបានចុះបញ្ជីហើយ ។

*ខ.២ ឯកសារតម្រូវចាំបាច់*

ក្រោមសេចក្តីប្រកាសលេខ ២៩៩ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការអនុវត្តនីតិវិធីថ្មីនៃការចុះបញ្ជីក្រុមហ៊ុនដែលមានទីស្នាក់ការនៅព្រះរាជាណាចក្រកម្ពុជា គឺត្រូវឱ្យឈ្មោះតាមរយៈក្រសួងពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិ ។ ហើយឯកសារទាមទារគឺត្រូវមានៈ

-ឯកសារដែលបញ្ជាក់អំពីអាសយដ្ឋាន ដែលមាននៅក្នុងក្រដាសបង់ទឹក ឬភ្លើង ឬកិច្ចសន្យាជួលផ្ទះ ឬអាគារ និងឯកសារបញ្ជាក់របស់ធនាគារជាដើម ។

-អនុស្សរណៈនៃការយោគយល់គ្នានៃការបង្កើតក្រុមហ៊ុន ប្រសិនបើមានគ្នាច្រើន ។

-រូបថត ៤×៦ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ម្ចាស់ក្រុមហ៊ុន និងអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុន ។

-ត្រូវមានលិខិតថ្កោលទោស និងសេចក្តីបញ្ជាក់ពីភាពត្រឹមត្រូវថាមិនមានបញ្ហាជាមួយនឹងក្រុមហ៊ុនមុនៗ ចំពោះអ្នកគ្រប់គ្រងក្រុមហ៊ុន និងបញ្ជាក់អំពីភាពមិនមែនជាមន្ត្រីរាជការដែលមិនស្ថិតក្រោមច្បាប់ស្តីពីមន្ត្រីរាជការស៊ីវិលនៃប្រទេសកម្ពុជា ។

-ក្នុងករណីដែលក្រុមហ៊ុននោះជានីតិបុគ្គល ឬក្រុមហ៊ុនចម្បងត្រូវបង្ហាញពីភាពស្របច្បាប់នៃក្រុមហ៊ុនមេនោះ (ការចុះបញ្ជី) ។ លិខិតដើមតែងតាំងផ្លូវការពីម្ចាស់ក្រុមហ៊ុនពីនីតិបុគ្គលនោះក្នុងការធ្វើជាតំណាង ។

ក្រុមហ៊ុនដែលនឹងត្រូវធ្វើការចុះបញ្ជីថ្មី ឬក្រុមហ៊ុនដែលនឹងត្រូវបង្កើតសាខាថ្មីត្រូវថតចម្លងនូវលក្ខន្តិកៈក្រុមហ៊ុនចំនួន ០២ច្បាប់ ដោយភ្ជាប់ជាមួយនឹងឯកសារធនាគារអំពីការតម្កល់ដើមទុនទៅនាយកដ្ឋានចុះបញ្ជីនៃក្រសួងពាណិជ្ជកម្មចំនួន ៣០ថ្ងៃ នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្រត្រូវចេញជូនអ្នកស្នើសុំ ។ ក្នុងអំឡុងពេលនេះ ប្រសិនបើនាយកដ្ឋានមិនទទួលបានច្បាប់ថតចម្លងដើមពីលក្ខន្តិកៈទេ នាយកដ្ឋាននឹងរក្សាសិទ្ធិលុប ឬទាត់ចោលការស្នើសុំ និងលុបអ្វីៗទាំងអស់ចេញពីទិន្នន័យដែលមានចេញពីនាយកដ្ឋាន[៣៣] ។

[៣៣] http://bizdoctors.asia/ចង់ចុះបញ្ជីក្រុមហ៊ុន។

### គ. ការវិនិច្ឆ័យចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

ការវិនិច្ឆ័យម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រមានលក្ខណៈដូចគ្នាទៅនឹងម៉ាកធម្មតាដែរ ប៉ុន្តែមានចំណុចមួយចំនួនដែលមានលក្ខណៈខុសពីម៉ាកធម្មតាដូចរៀបរាប់ខាងក្រោម ៖

ចំពោះអ្នកដាក់ពាក្យស្នើសុំសមាគមសម្គាល់ភូមិសាស្ត្រ ឬក្រុមតំណាងផលិតករ ឬអង្គភាពតំណាងផលិតករ និង/ឬប្រតិបត្តិករដែលទទួលផលប្រយោជន៍ពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនោះមានសិទ្ធិដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។ ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា ត្រូវធ្វើតាមរយៈសមាគមសម្គាល់ភូមិសាស្ត្រទំនិញ ។ អ្នកដាក់ពាក្យស្នើសុំគឺជាម្ចាស់សិទ្ធិលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញក្រោយការចុះបញ្ជី ។

ក្រុមផលិតករ ប្រតិបត្តិករ ស្ថាប័ន និង/ឬបុគ្គលពាក់ព័ន្ធដែលមានបំណងចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា ត្រូវរៀបចំបង្កើតជាសមាគមសម្គាល់ភូមិសាស្ត្រទំនិញដោយផ្អែកលើតំបន់ភូមិសាស្ត្រ និងមុខទំនិញមួយ ហើយត្រូវមានលក្ខន្តិកៈដើម្បីគ្រប់គ្រង និងចាត់ចែងការងាររបស់ខ្លួនក្នុងគោលដៅមិនរកប្រាក់ចំណេញ ។ សមាជិកភាពរបស់សមាគមត្រូវមានលក្ខណៈបើកចំហ ។ សមាគមសម្គាល់ភូមិសាស្ត្រទំនិញត្រូវមានការទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច ។ រាល់លក្ខន្តិកៈរបស់សមាគមត្រូវយកមកតម្កល់នៅក្រសួងពាណិជ្ជកម្ម ។ សមាគមត្រូវធានាឱ្យសមាជិករបស់ខ្លួនអនុវត្តតាមសៀវភៅបន្ទុក និងកាតព្វកិច្ចផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងបទបញ្ញត្តិជាធរមាន[៣៤] ។ ហើយពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ត្រូវដាក់នៅក្រសួងពាណិជ្ជកម្ម ដោយភ្ជាប់មកជាមួយនូវសៀវភៅបន្ទុក និងសំណុំឯកសារពាក់ព័ន្ធ ។ ទម្រង់បែបបទនៃការដាក់ពាក្យស្នើសុំគំរូសៀវភៅបន្ទុក និងសំណុំឯកសារពាក់ព័ន្ធសម្រាប់ការចុះបញ្ជីត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម[៣៥] ។

ការពិនិត្យពាក្យស្នើសុំចុះបញ្ជី ក្រសួងពាណិជ្ជកម្មត្រូវពិនិត្យពាក្យស្នើសុំនឹងត្រូវឆ្លើយតបក្នុងរយៈពេលយ៉ាងយូរ ៩៥ថ្ងៃគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ ។ បន្ទាប់ពីពិនិត្យឃើញថា ពាក្យស្នើសុំបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដែលបានកំណត់ ក្រសួងពាណិជ្ជកម្មត្រូវចេញលិខិតទទួលស្គាល់ការដាក់ពាក្យស្នើសុំនោះជាផ្លូវការ ។

ក្នុងករណីការពិនិត្យឃើញថា ពាក្យស្នើសុំមិនបានបំពេញគ្រប់គ្រាន់តាមលក្ខខណ្ឌដែលបានកំណត់របស់ក្រសួងពាណិជ្ជកម្មត្រូវចេញលិខិតឱ្យអ្នកដាក់ពាក្យស្នើសុំដើម្បីធ្វើការបំពេញបន្ថែម ឬកែតម្រូវដោយបញ្ជាក់ពីចំណុចខ្វះខាត ។ អ្នកដាក់ពាក្យស្នើសុំអាចធ្វើការបំពេញបន្ថែម ឬកែតម្រូវពាក្យស្នើសុំក្នុងរយៈពេល ០៦ខែគិតចាប់ពីថ្ងៃចេញលិខិត ។ ពាក្យស្នើសុំចុះបញ្ជីនោះត្រូវចាត់ទុកថាបានបោះបង់ចោលប្រសិនបើគ្មានការបំពេញបន្ថែម ឬការកែតម្រូវ ឬមិនបានផ្តល់ការឆ្លើយតប ឬ

[៣៤] ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ, នស/រកម/០១១៤/០០៦, ២០.មករា.២០១៤, មាត្រា១៧។
[៣៥] ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ, នស/រកម/០១១៤/០០៦, ២០.មករា.២០១៤, មាត្រា៨។

ការពន្យល់ជាវិជ្ជមានក្នុងរយៈពេលដែលបានកំណត់ខាងលើ ។ ក្រសួងពាណិជ្ជកម្មអាចពន្យាពេលបន្ថែម ០៦ខែទៀតសម្រាប់កែតម្រូវពាក្យស្នើសុំ ប្រសិនមានសំណូមពរសមហេតុផលពីអ្នកដាក់ពាក្យស្នើសុំ ។

ក្រសួងពាណិជ្ជកម្មត្រូវពិនិត្យឯកសារបំពេញបន្ថែម ឬឯកសារកែតម្រូវនេះ និងត្រូវឆ្លើយតបក្នុងរយៈពេលយ៉ាងយូរ ៤៥ថ្ងៃគិតចាប់ពីថ្ងៃទទួលឯកសារបំពេញបន្ថែម ឬឯកសារកែតម្រូវនេះ[៣៦]។

ការត្រួតពិនិត្យខ្លឹមសារនៃពាក្យស្នើសុំលើចំណុចសំខាន់ៗដូចជា៖ (១)ភាពត្រឹមត្រូវនៃពត៌មានលម្អិតក្នុងពាក្យស្នើសុំដូចមានចែងក្នុងមាត្រា ៧ និងមាត្រា ៨ នៃច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ (២)ចំណុចទាំងឡាយដូចមានចែងក្នុងមាត្រា ៤ ត្រង់ចំណុចនិយមន័យលើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងមាត្រា ១០ (៣)ភាពជាក់ស្ដែងនៅមូលដ្ឋានផលិតកម្ម ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ (៤)ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលមានសូរសំឡេងដូចគ្នាត្រូវអនុវត្តតាមលក្ខខណ្ឌដែលកំណត់ដោយក្រសួងពាណិជ្ជកម្ម ។

ក្នុងករណីការត្រួតពិនិត្យខ្លឹមសារនៃពាក្យស្នើសុំ ក្រសួងពាណិជ្ជកម្មអាចអញ្ជើញអ្នកដាក់ពាក្យស្នើសុំ ឬបុគ្គលដែលមានការពាក់ព័ន្ធមកពន្យល់ ឬផ្តល់ភស្តុតាងបន្ថែម ។ ក្នុងករណីចាំបាច់ក្រសួងពាណិជ្ជកម្មអាចស្នើសុំមតិពីអ្នកជំនាញក្នុងវិស័យពាក់ព័ន្ធដើម្បីធ្វើការពិនិត្យពិចារណា និងសម្រេច[៣៧] ។

**ឃ. ការវិនិច្ឆ័យចំពោះម៉ាកសមូហភាព**

ការវិនិច្ឆ័យចំពោះម៉ាកសមូហភាព មានលក្ខណៈដូចគ្នានឹងនីតិវិធីក្នុងការវិនិច្ឆ័យម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែរ ។ ចំណុចចាំបាច់បំផុតនោះ គឺម៉ាកសមូហភាព គឺត្រូវរក្សាឱ្យបានលក្ខណៈជារបស់ខ្លួនមានលក្ខណៈខុសពីរបស់អ្នកដទៃទាំងរូបមន្ត ទាំងគុណភាព ហើយអាចសម្គាល់នូវប្រភពដើមនៃទំនិញ ឬសេវា ឬសម្គាល់នូវចរិតលក្ខណៈរួមដទៃទៀតគិតទាំងគុណភាពនៃទំនិញ ឬសេវារបស់សហគ្រាសផ្សេងៗគ្នា ដែលប្រើសញ្ញានោះ ។

ប្រសិនបើមន្ត្រីកាន់កាប់បញ្ជី បានពិនិត្យឃើញថាពាក្យស្នើសុំចុះបញ្ជីមិនទាន់បានបំពេញបានត្រឹមត្រូវ ឬក៏មានចំណុចណាដែលមិនសមស្របនឹងមាត្រា ៨ ចំណុច ២ នៃច្បាប់ស្ដីពីម៉ាក ឬក៏ចំណុចណាដែលត្រូវកែសម្រួល មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅដល់ម្ចាស់ម៉ាក អំពីមូលហេតុនៃការច្រានចោលនោះ ដោយភ្ជាប់នូវពត៌មានលម្អិតទាំងអស់ ដែលបានពាក់ព័ន្ធនឹងសេចក្ដីសម្រេចរបស់ខ្លួន ហើយស្នើសុំឱ្យអ្នកដាក់ពាក្យធ្វើការកែតម្រូវពាក្យស្នើសុំចុះបញ្ជីរបស់ខ្លួន និងផ្ញើចម្លើយតបទៅនឹងមន្ត្រីកាន់កាប់បញ្ជីជាលាយលក្ខណ៍អក្សររយៈពេល ៤៥ថ្ងៃ បន្ទាប់ពីបានសេចក្ដីជូនដំណឹងរបស់មន្ត្រីកាន់កាប់បញ្ជី ។ ក្នុងករណីនេះម្ចាស់ម៉ាកមានសិទ្ធិ

[៣៦] ច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ, នស/រកម/០១១៤/០០៦, ២០.មករា.២០១៤, មាត្រា៩។

[៣៧] ច្បាប់ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ, នស/រកម/០១១៤/០០៦, ២០.មករា.២០១៤, មាត្រា១១។

ក្នុងការកែសម្រួលពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួន ក្នុងរយៈពេល ៩៥ថ្ងៃ ប្រសិនបើផុតរយៈពេល ៩៥ថ្ងៃនេះហើយ ម្ចាស់ម៉ាកនៅតែមានសិទ្ធិកែតម្រូវពាក្យស្នើសុំរបស់ខ្លួនទៀត មន្ត្រីកាន់កាប់បញ្ជីមានសិទ្ធិបដិសេធការចុះបញ្ជីម៉ាកនោះ ។

ក្នុងករណីដែលអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីបានឯកភាពគ្នាជាមួយ និងមន្ត្រីកាន់កាប់បញ្ជី អ្នកស្នើសុំត្រូវតែជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីវិញ ជាលាយលក្ខណ៍អក្សរ ហើយធ្វើការកែតម្រូវពាក្យស្នើសុំរបស់ខ្លួន ទៅតាមសេចក្តីជូនដំណឹងរបស់មន្ត្រីកាន់កាប់បញ្ជីម៉ាកខាងលើ ។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើអ្នកស្នើសុំចុះបញ្ជី មិនយល់ស្របនឹងសេចក្តីជូនដំណឹងរបស់មន្ត្រីកាន់កាប់បញ្ជី ហើយមិនបានឆ្លើយតបតាមការកំណត់របស់មន្ត្រីកាន់កាប់បញ្ជីនោះ អាចសន្មតបានថាអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីបានបោះបង់ចោលពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួនហើយ ។

ក្នុងករណីមួយទៀតប្រសិនបើអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកមិនយល់ស្រប មិនឯកភាព ឬចង់បដិសេធទៅនឹងសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី ម្ចាស់ម៉ាកមានសិទ្ធិដាក់ពាក្យស្នើសុំសវនការមួយ ឬផ្តល់នូវការយល់ឃើញរបស់ខ្លួនជាលាយលក្ខណ៍អក្សរទៅកាន់មន្ត្រីកាន់កាប់បញ្ជី ក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីសម្រេចមន្ត្រីកាន់កាប់បញ្ជី ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងរបស់អ្នកដាក់ពាក្យស្នើសុំឱ្យបើកសវនការហើយ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកយូរ ០១ខែ មុនកាលបរិច្ឆេទដែរអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកចូលក្នុងសវនការ ។

បន្ទាប់ពីមានសវនការ ហើយមន្ត្រីកាន់កាប់បញ្ជីនៅតែបដិសេធមិនព្រមទទួលចុះបញ្ជីហើយច្រានចោលពាក្យចុះបញ្ជីនោះទៀត មន្ត្រីកាន់កាប់បញ្ជីត្រូវតែជូនដំណឹងអំពីសេចក្តីបដិសេធរបស់ខ្លួនជាលាយលក្ខណ៍អក្សរទៅដាក់ពាក្យស្នើសុំ ។ លើសពីនេះទៅទៀត អ្នកដាក់ពាក្យស្នើសុំមានសិទ្ធិទាមទារឱ្យមន្ត្រីកាន់កាប់បញ្ជីបញ្ជាក់ពីមូលហេតុ និងឯកសារដែលពាក់ព័ន្ធដែលមន្ត្រីកាន់កាប់បញ្ជីសម្រេចមិនព្រមចុះបញ្ជី ក្នុងរយៈពេល ០១ខែ បន្ទាប់ពីទទួលបានសេចក្តីសម្រេច ។

លើសពីនេះទៅទៀត ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីនៅតែបដិសេធមិនព្រមទទួលចុះបញ្ជីទៀត ហើយដាក់ពាក្យស្នើសុំ ចុះបញ្ជីនៅតែមិនឯកភាពនឹងសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីមានសិទ្ធិប្តឹងទៅក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា ឬក៏ប្តឹងទៅតុលាការក៏បានដែរ ក្នុងរយៈពេល ០៣ខែ គិតចាប់ពីថ្ងៃដែលគាត់ទទួលបានសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី ។ ប្រសិនបើក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ានៅតែបដិសេធការចុះបញ្ជីនោះទៀតអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី មានសិទ្ធិប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយវិវាទទៅតុលាការដែលមានសមត្ថកិច្ច ក្នុងរយៈពេល ០៣ខែ គិតពីថ្ងៃដែលចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបណ្តឹងតវ៉ា (ដោយសារតែកម្ពុជាយើងមិនទាន់មានក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា

នៅឡើយទេ ដូចនេះនីតិវិធីនៃការដាក់ពាក្យបណ្តឹងតវ៉ា គឺអ្នកដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីទាស់ជាមួយនឹងសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី) ។

### ២.២.២ សិទ្ធិ និងភារកិច្ចរបស់មន្ត្រីចុះបញ្ជីម៉ាក និងការពារម៉ាក

នៅពេលដែលមន្ត្រីកាន់កាប់បញ្ជីទទួលពាក្យស្នើសុំចុះបញ្ជីនីមួយៗ គេត្រូវកត់ត្រានៅលើសំណុំឯកសារ នៃពាក្យស្នើសុំចុះបញ្ជីម៉ាកនីមួយៗនូវកាលបរិច្ឆេទពិតប្រាកដ និងលេខរៀងនៃការដាក់ពាក្យស្នើសុំចុះបញ្ជីនោះ ។ លើសពីនេះទៅទៀត មន្ត្រីកាន់កាប់បញ្ជីត្រូវត្រួតពិនិត្យលើពាក្យស្នើសុំរួចហើយ ដោយអនុវត្តតាមមាត្រា ៨ ចំនុច "ខ" នៃច្បាប់ស្តីពីម៉ាក មន្ត្រីកាន់កាប់បញ្ជីត្រូវត្រួតពិនិត្យមើលនូវពត៌មានថាគ្រប់គ្រាន់ និងត្រឹមត្រូវហើយឬនៅ ។ ពិនិត្យនូវចំណុចដូចខាងក្រោម (១)ឈ្មោះរបស់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក (២)អាសយដ្ឋានសម្រាប់ទំនាក់ទំនង (៣)គំរូម៉ាកដែលស្នើសុំចុះបញ្ជី (៣)យថាប្រភេទរបស់ទំនិញ ឬសេវាដែលស្នើសុំចុះបញ្ជីក្នុងចំណោមថ្នាក់នីមួយៗ ។ (៤)កម្រៃនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលតម្រូវសម្រាប់ ចំណាត់ថ្នាក់នីមួយៗនៃទំនិញ ឬសេវាកម្មដែលស្នើសុំចុះបញ្ជីម៉ាក ។

បន្ទាប់ពីបានត្រួតពិនិត្យពាក្យស្នើសុំចុះបញ្ជីចប់សព្វគ្រប់រួចមក និងយល់ឃើញថាម៉ាកនោះពិតជាត្រឹមត្រូវតាមទម្រង់ និងបែបបទខាងលើហើយមន្ត្រីកាន់កាប់បញ្ជីម៉ាកយល់ព្រមចុះបញ្ជីម៉ាកនោះហើយ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីម៉ាក និងចេញវិញ្ញាបនបត្រ នៃការចុះបញ្ជីម៉ាកជូនអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ហើយត្រូវបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកនោះ នៅក្នុងព្រឹត្តិប័ត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម ។

យោងតាមមាត្រា ៥ ចំណុច "ខ" នៃច្បាប់ស្តីពីម៉ាកបានចែងថា "ការសុំចុះបញ្ជីម៉ាកការសុំប្តូរអាសយដ្ឋាននៃម្ចាស់ម៉ាក និងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក ត្រូវបង់កម្រៃ តាមការកំណត់នៅក្នុងសេចក្តីប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងក្រសួងពាណិជ្ជកម្ម លេខ ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧" ។ ដូចនេះនៅពេលដែលមានការយល់ព្រមទទួលចុះបញ្ជី ពីសំណាក់មន្ត្រីកាន់កាប់បញ្ជីរួចហើយ ម្ចាស់ម៉ាកត្រូវតែមានកាតព្វកិច្ចបង់ថ្លៃសេវានៃការចុះបញ្ជីម៉ាកនោះ នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា ។ តម្លៃនៃសេវាដែលត្រូវបង់នោះ គឺត្រូវកំណត់ក្នុងប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ។

តារាងស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម (នាយកដ្ឋានកម្មសិទ្ធិបញ្ញា)

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេលផ្តល់សេវា(ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| ១ | ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងការត្រួតពិនិត្យម៉ាកលម្អិត | ១៦០ ០០០៛ | ៦ខែ ទៅ ៩ខែ | ១០ ឆ្នាំ |
| ២ | ការចុះបញ្ជីម៉ាក និងបោះពុម្ពផ្សាយ | ២៦០ ០០០៛ | ៦ខែ ទៅ ៩ខែ | ១០ ឆ្នាំ |
| ៣ | ការដាក់ពាក្យស្នើសុំ ការត្រួតពិនិត្យលម្អិត ការចុះបញ្ជីនិងការបោះពុម្ពផ្សាយ សម្រាប់ម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្ម | ៤២០ ០០០៛ | ៦ខែ ទៅ ៩ខែ | ១០ ឆ្នាំ |
| ៤ | ការដាក់ពាក្យស្នើសុំ ការត្រួតពិនិត្យលម្អិត ការចុះបញ្ជីនិងបោះពុម្ពផ្សាយសម្រាប់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ | ៤២០ ០០០៛ | ៦ខែ ទៅ ១២ខែ | អចិន្ត្រៃយ៍ |
| ៥ | ការដាក់ពាក្យស្នើសុំ បញ្ជាក់ពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាកម៉ាកសមូលហភាព ម៉ាកវិញ្ញាតកម្មឬម៉ាកក្នុងក្របខណ្ឌអន្តរជាតិ | ១០០ ០០០៛ | ៦០ថ្ងៃ | ៥ ឆ្នាំ |
| ៦ | ការផ្លាស់ប្តូរផ្សេងៗ | ១០០ ០០០៛ | ៦០ថ្ងៃ | អចិន្ត្រៃយ៍ |
| ៧ | ការស្នើសុំពន្យាពេលផ្តល់ទឡ្ហីករណ៍ ឬ ឯកសារគាំទ្រផ្សេងៗ (ចាប់ពីលើកទី២ឡើងទៅ) | ៤០ ០០០៛ | ១០ថ្ងៃ | |
| ៨ | ការដាក់ពាក្យស្នើសុំ និងពិនិត្យបណ្តឹងជំទាស់ ធ្វើមោឃភាពឬលុបការចុះបញ្ជីម៉ាក ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ សិទ្ធិផ្តាច់មុខ ឬអាជ្ញាប័ណ្ណ អាជ្ញាប័ណ្ណពិសេស ចេញពីបញ្ជី | ៣០០ ០០០៛ | ៦០ថ្ងៃ | |
| ៩ | ការលុបម៉ាក ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ សិទ្ធិផ្តាច់មុខ ឬអាជ្ញាប័ណ្ណ អាជ្ញាប័ណ្ណពិសេសចេញពីបញ្ជី និងការបោះពុម្ពផ្សាយ | ៣០០ ០០០៛ | តាមករណី | |

| | | | | |
|---|---|---|---|---|
| ១០ | ការដាក់ពាក្យ ការចុះបញ្ជីសាជាថ្មី និងបោះពុម្ពផ្សាយម៉ាក ម៉ាកសមូហភាព ឬវិញ្ញាតកម្ម | ៤២០ ០០០៛ | ៦០ថ្ងៃ | ១០ ឆ្នាំ |
| ១១ | ការស្នើសុំកត់ត្រា និងប្រគល់លិខិតសិទ្ធិផ្តាច់មុខ | ៦០០ ០០០៛ | ៦០ថ្ងៃ | មិនលើស២ ឆ្នាំ |
| ១២ | ការស្នើសុំកត់ត្រាអាជ្ញាប័ណ្ណ អាជ្ញាប័ណ្ណពិសេស | ៤០០ ០០០៛ | ៦០ថ្ងៃ | តាមកិច្ចសន្យាអាជ្ញាប័ណ្ណ |
| ១៣ | ការស្នើសុំលុបម៉ាក ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម ម៉ាកសម្គាល់ភូមិសាស្ត្រ ទំនិញ ការកត់ត្រាសិទ្ធិផ្តាច់មុខ ឬការកត់ត្រាអាជ្ញាប័ណ្ណ អាជ្ញាប័ណ្ណពិសេស ដោយម្ចាស់ម៉ាក ឬភ្នាក់ងារតំណាង | ១២០ ០០០៛ | ៦០ថ្ងៃ | |
| ១៤ | ការស្នើសុំពិនិត្យ និងវាយតម្លៃម៉ាក មុនការដាក់ពាក្យស្នើសុំចុះបញ្ជី | ៨០ ០០០៛ | ៦០ថ្ងៃ | |
| ១៥ | ការស្នើសុំទុតិយតាវិញ្ញាបនបត្រ ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ថតចម្លងឯកសារ ការបញ្ជាក់សុពលភាពម៉ាក ឬការបញ្ជាក់ផ្សេងៗ | ១០០ ០០០៛ | ៦០ថ្ងៃ | |
| ១៦ | ការដាក់ពាក្យស្នើសុំសម្រុះសម្រួលវិវាទ | ២០០ ០០០៛ | ៣០ថ្ងៃ | |
| ១៧ | ការវាយតម្លៃអំពីការរំលោភបំពាន | ២០០ ០០០៛ | ៦០ថ្ងៃ | |
| ១៨ | ការពិន័យការបង់ប្រាក់ចុះបញ្ជីយឺតលើស ៦០ថ្ងៃ បន្ទាប់ពីថ្ងៃជូនដំណឹង ( លើសពី ១២០ថ្ងៃ ចាត់ទុកថាបោះបង់ចោល ) | | | |
| | -ពី ៦១ថ្ងៃ ដល់ ៩០ថ្ងៃ | ៨០ ០០០៛ | តាមករណី | |
| | -ពី ៩១ថ្ងៃ ដល់១២០ថ្ងៃ | ២០០ ០០០៛ | តាមករណី | |

| | | | | |
|---|---|---|---|---|
| ១៩ | ការពិន័យចំពោះការស្នើសុំចុះបញ្ជីម៉ាកសារជាថ្មីយឺតយ៉ាវ ក្នុងអំឡុងពេល៦ខែ (តាមមាត្រា១២ "ឃ" នៃច្បាប់ស្តីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ) | ២០០ ០០០៛ | តាមករណី | |
| ២០ | ការបញ្ជាក់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ក្នុងមួយជំពូក | ១០០ ០០០៛ | ៦០ថ្ងៃ | |
| ២១ | ការស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិដែលកម្ពុជាត្រូវបានជ្រើសរើសក្នុងមួយជំពូក និងបោះពុម្ពផ្សាយ | ៦០០ ០០០៛ | តាមបទប្បញ្ញត្តិរួមនៃការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ | ១០ឆ្នាំ |
| ២២ | ការស្នើសុំចុះបញ្ជីម៉ាកក្នុងក្រមខណ្ឌអន្តរជាតិសាជាថ្មី ក្នុងមួយជំពូក | ៦០០ ០០០៛ | តាមបទប្បញ្ញាត្តិរួមនៃការចុះបញ្ជីម៉ាក ក្នុងក្របខណ្ឌអន្តរជាតិ | ១០ឆ្នាំ |
| ២៣ | ការសុំប្តូរម៉ាកក្នុងក្រមខណ្ឌអន្តរជាតិទៅជាម៉ាកថ្នាក់ជាតិ និងបោះពុម្ពផ្សាយ | ៤២០ ០០០៛ | តាមបទប្បញ្ញាត្តិរួមនៃការចុះបញ្ជីម៉ាក ក្នុងក្របខណ្ឌអន្តរជាតិ | ១០ឆ្នាំ |
| ២៤ | ការជំនួសម៉ាកជាតិទៅជាម៉ាកក្នុងក្របខណ្ឌអន្តរជាតិ និងបោះពុម្ពផ្សាយ | ១០០ ០០០៛ | តាមបទប្បញ្ញាត្តិរួមនៃការចុះបញ្ជីម៉ាក ក្នុងក្របខណ្ឌអន្តរជាតិ | ១០ឆ្នាំ |

| | | | | |
|---|---|---|---|---|
| ២៥ | ការស្នើសុំទទួលស្គាល់ជាភ្នាក់ងារតំណាងម្ចាស់ម៉ាក | ១០០ ០០០៛ | តាមបទប្បញ្ញត្តិរួមនៃការចុះបញ្ជីក្នុងក្របខណ្ឌអន្តរជាតិ | ១ឆ្នាំ |

ការចុះបញ្ជីម៉ាកនៃទំនិញ ឬសេវាកម្មត្រូវចុះទៅតាមចំណាត់ថ្នាក់ដែលមានកំណត់នៅក្នុងកិច្ចព្រមព្រៀងសន្និសញ្ញាទីក្រុងប៉ារីស ដែលបានបែងចែកប្រភេទនៃចំណាត់ថ្នាក់ទំនិញ និងរាល់សេវាផ្សេងៗគ្នា ទៅតាមប្រភេទនៃទំនិញ ឬសេវាកម្មនីមួយៗ ។ នៅក្នុងកិច្ចព្រមព្រៀងនេះផងដែរ បានចែងក្នុងចំណាត់ថ្នាក់នៃម៉ាកដែលជាទំនិញជា ៣៤ចំណាត់ថ្នាក់ និងម៉ាកដែលជាសេវាចំនួន ១១ ចំណាត់ថ្នាក់[៣៨] ។

ក្រោយពីម្ចាស់ម៉ាកបានបំពេញលក្ខខណ្ឌខាងលើគ្រប់គ្រាន់ហើយ មន្ត្រីចុះបញ្ជីម៉ាកមានសិទ្ធិ និងកាតព្វកិច្ចដូចតទៅ(មាត្រា៩)៖ (១)មានសិទ្ធិចេញវិញ្ញាបនបត្រនៃការចុះបញ្ជី ករណីពិនិត្យឃើញថា ម៉ាកសុំចុះបញ្ជីមានលក្ខណៈគ្រប់គ្រាន់តាមច្បាប់ (២)ចំពោះម៉ាក ដែលមានលក្ខណៈមិនសមស្របតាមច្បាប់ មន្ត្រីកាន់កាប់បញ្ជីមានសិទ្ធិជូនដំណឹង ឱ្យកែសម្រួលម៉ាកឡើងវិញ ហើយការកែសម្រួលម៉ាក ក្នុងរយៈពេល៤៥ថ្ងៃ (៣)ករណីមិនមានការកែសម្រួលម៉ាកតាមកាលកំណត់របស់មន្ត្រីកាន់កាប់បញ្ជីមានសិទ្ធិបដិសេធការចុះបញ្ជីនោះ (៤)មន្ត្រីកាន់កាប់បញ្ជីមានសិទ្ធិជូនដំណឹងដល់អ្នកសុំចុះបញ្ជីម៉ាក ក្នុងករណីមើលឃើញថាម៉ាកមិនបានគោរពតាមការកំណត់នៃច្បាប់ដោយទុកពេលឱ្យប្តឹងទាស់រយៈពេល៩០ថ្ងៃ គិតពីថ្ងៃបានចុះផ្សាយក្នុងព្រឹត្តិបត្រជាផ្លូវការ (ករណីម៉ាកដូចឬម៉ាកប្រហាក់ប្រហែលគ្នា) (ក) មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងជាបន្ទាន់ ដោយធ្វើការកំណត់ពេលវេលា និងភ្ជាប់បែបបទ ក្នុងករណីអ្នកស្នើសុំចុះបញ្ជីបានឆ្លើយតបក្នុងរយៈពេល៩០ថ្ងៃខាងលើតែមានបញ្ហា ។ ប្រសិនបើអ្នកសុំចុះបញ្ជីមិនឆ្លើយតបករណីនេះទេ មានន័យថា គាត់បោះបង់ចោលការសុំចុះបញ្ជីរបស់ខ្លួន។ (ខ) ករណីអ្នកសុំចុះបញ្ជី ធ្វើពាក្យជំទាស់ មន្ត្រីកាន់កាប់បញ្ជីត្រូវឆ្លើយតបការជំទាស់នោះ។ (គ) ប្រសិនបើជាភាគីម្ខាង ឬទាំងសងខាង មានបំណងចង់ឱ្យមានសវនាការ មន្ត្រីកាន់កាប់បញ្ជី ត្រូវរៀបចំសវនាការនោះ។ បន្ទាប់ពីបានស្តាប់ភាគីទាំងសងខាង និងពិចារណាលើពាក្យតវ៉ា មន្ត្រីកាន់កាប់បញ្ជី ត្រូវសម្រេច ម៉ាកដែលត្រូវចុះបញ្ជី ឬត្រូវរក្សាទុក ឬត្រូវបដិសេធ ។

[៣៨] ដកស្រង់ចេញពីតារាងស្តីពីឧបសម្ព័ន្ធភ្ជាប់និងប្រកាសរួមលេខ ១២១៧ សហវ.ប្រក ចុះថ្ងៃ២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

មន្ត្រីកាន់កាប់បញ្ជីម៉ាកមានសិទ្ធិផ្តល់អាជ្ញាប័ណ្ណ ចំពោះម៉ាកដែលត្រឹមត្រូវតាមលក្ខខណ្ឌ៖ (១) កិច្ចសន្យាអាជ្ញាប័ណ្ណអំពីការចុះបញ្ជីម៉ាក ត្រូវមានចែងពីការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពពីគុណភាពទំនិញ និងសេវា ។ បើអាជ្ញាប័ណ្ណមិនមានចែងអំពីការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពពីគុណភាពទំនិញ និងសេវា អាជ្ញាប័ណ្ណនោះត្រូវចាត់ទុកមិនបានការ (២)ពាក្យស្នើសុំចុះបញ្ជីម៉ាកជាសម្ងាត់ មិនអាចជាកម្មវត្ថុនៃកិច្ចសន្យាអាជ្ញាប័ណ្ណបានឡើយ។ លើសពីនេះមន្ត្រីចុះបញ្ជីម៉ាកក៏មានសិទ្ធិមោឃភាពម៉ាក នូវម៉ាកដែលមានការពាក់ព័ន្ធ អាចស្នើសុំមកក្រសួងពាណិជ្ជកម្មឱ្យផ្តល់មោឃភាពដល់ការចុះបញ្ជីម៉ាកបាន ។

## ២.៣ ស្ថាប័នពាក់ព័ន្ធការពារម៉ាក

### ២.៣.១ សិទ្ធិ និងភារកិច្ចស្ថាប័នពាក់ព័ន្ធក្នុងការការពារម៉ាក

ម៉ាកបានចុះបញ្ជីរួចត្រូវបានការពារដោយច្បាប់ ។ ម្ចាស់ម៉ាកដែលចុះបញ្ជីរួចអាចធ្វើពាក្យបណ្តឹងតាមរដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ឱ្យរឹបអូសទុកនូវរាល់ការធ្វើបែបបទទំនិញណា ដែលម្ចាស់ម៉ាកសង្ស័យថា មានម៉ាកក្លែងក្លាយ ដោយបង្ហាញនូវភស្តុតាងច្បាស់លាស់ថា គាត់ជាម្ចាស់នៃម៉ាកដែលបានចុះបញ្ជី ។ ពាក្យបណ្តឹងត្រូវភ្ជាប់៖ (១)វិញ្ញាបនបត្រចុះបញ្ជីម៉ាក (២)សេចក្តីថ្លែងពីមូលហេតុនៃការប្តឹង ជាពិសេសភស្តុតាងដែលបង្ហាញទំនិញនោះពាក់ម៉ាកក្លែងក្លាយមែន (៣)ការរៀបរាប់ដ៏លម្អិត ពីទំនិញដែលម៉ាករបស់វាត្រូវបានប្រើប្រាស់ព្រមទាំងគំរូនៃផលិតផលពិតប្រាកដ ប្រសិនបើមានសំណូមពរ (៤)ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាងជាភ្នាក់ងារ ដែលត្រូវរៀបរាប់ឱ្យបានសព្វគ្រប់តាមការកំណត់ (៥)លិខិតអនុញ្ញាតពីម្ចាស់ម៉ាកដែលបានចុះបញ្ជី ប្រសិនបើពាក្យបណ្តឹងនោះត្រូវបានដាក់ដោយតំណាងដែលទទួលសិទ្ធិ (៦) កម្រៃរដ្ឋបាល តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

#### ក. វិធានបណ្តោះអាសន្នរបស់ស្ថាប័នតុលាការ

តុលាការអាចចេញសេចក្តីសម្រេចបណ្តោះអាសន្ន តាមសំណើរបស់ម្ចាស់ម៉ាក ឬអ្នកទទួលអាជ្ញាប័ណ្ណដើម្បីទប់ស្កាត់ការរំលោភ ឬទង្វើមិនស្របច្បាប់ ។ ក្នុងករណីដែលអ្នកទទួលអាជ្ញាប័ណ្ណស្នើទៅម្ចាស់ម៉ាកឱ្យប្តឹងទៅតុលាការដើម្បីជួសជុលសំណងជាក់លាក់មួយ តែម្ចាស់ម៉ាកបដិសេធ ឬខកខានមិនបានធ្វើតាម អ្នកទទួលអាជ្ញាប័ណ្ណអាចប្តឹងទៅតុលាការដោយផ្ទាល់បាន។

តុលាការអាចចេញសេចក្តីសម្រេច ឱ្យមានការជុសជុលសំណង ក្នុងករណីការប្រកួតប្រជែងមិនស្របច្បាប់របស់សមាគមសហាជីពនៃផលិតករ ឧស្សាហាករ ពាណិជ្ជករ តាមសំណើអាជ្ញាធរមានសមត្ថកិច្ច ។ តុលាការមានអំណាចដាក់ចេញនូវវិធានការបណ្តោះអាសន្នជាបន្ទាន់ និងមានប្រសិទ្ធភាពក្នុងការទប់ស្កាត់ការរំលោភបំពានដែលប្រុងនឹងកើតមានឡើង និងរក្សាទុកនូវភស្តុតាងដែលពាក់ព័ន្ធ ។

ចំពោះភាពយឺតយ៉ាវអាចអន្តរាយដល់ម្ចាស់សិទ្ធិ ឬនៅពេលភស្តុតាងអាចនឹងត្រូវបំផ្លាញ តុលាការអាចដាក់ចេញនូវវិធានការបណ្តោះអាសន្នប្រសិនបើដើមចោទផ្តល់នូវៈ (១)ភស្តុតាងត្រឹមត្រូវដែលមាន អាចឱ្យតុលាការយល់ស្របក្នុងកម្រិតមួយគ្រប់គ្រាន់សម្រាប់សន្និដ្ឋានបញ្ជាក់ថាដើមចោទជាម្ចាស់ពិតប្រាកដ ដែលកំពុងត្រូវបានគេរំលោភ ឬការរំលោភនឹងអាចកើតមាន ។ (២) ប្រាក់កក់ធានាដែលតម្រូវ ឬការធានាដែលមានតម្លៃស្មើប្រាក់កក់គ្រប់គ្រាន់ ក្នុងការការពារចុងចម្លើយ និងទប់ស្កាត់មិនឱ្យមានការរំលោភបំពាន (ប្រាក់កក់នេះ តុលាការជាអ្នកកំណត់) ។

ពេលដែលវិធានការបណ្តោះអាសន្នត្រូវបានដាក់ចេញតុលាការត្រូវជូនដំណឹងទៅចុងចម្លើយស្តីពីការចាត់វិធានការនេះ ។ ចុងចម្លើយមានសិទ្ធិប្តឹងទៅតុលាការ ស្នើសុំឱ្យពិនិត្យវិធានការនោះឡើងវិញ ក្នុងរយៈពេល១៥ថ្ងៃ (ថ្ងៃធ្វើការ) គិតពីថ្ងៃទទួលបានដំណឹងសេចក្តីសម្រេចពីតុលាការ ។ តុលាការអាចបើកសវនាការឱ្យភាគីពាក់ព័ន្ធ ហើយពិនិត្យឡើងវិញនូវវិធានការ និងត្រូវតម្កល់ ឬកែតម្រូវ ឬលុបចោលនូវសេចក្តីសម្រេចរបស់ខ្លួន ក្នុងរយៈពេលសមស្របតាមច្បាប់ ។

រយៈពេល២០ថ្ងៃ (ថ្ងៃធ្វើការ) គិតពីថ្ងៃទទួលដំណឹងនៃការដាក់ចេញវិធានការបណ្តោះអាសន្ន ដើមចោទមិនបានផ្តួចផ្តើមបន្តសំណុំរឿងបណ្តឹង តុលាការត្រូវលុបវិធានការបណ្តុះអាសន្ននោះចោល ដោយផ្អែកលើសំណើរបស់ចុងចម្លើយ ។

ករណីវិធានការត្រូវលុបចោល ឬតុលាការបានដំណើការតាមសំណើដើមចោទ តែមិនមានករណីរំលោភ នោះតុលាការសម្រេចឱ្យដើមចោទ សងរាល់ការខូចខាតនានា ដល់ចុងចម្លើយ ។

### ខ. វិធានតាមច្រកព្រំដែនរបស់ស្ថាប័នគយ

រយៈពេល១០ថ្ងៃ (ថ្ងៃធ្វើការ) បន្ទាប់ពីបានទទួលនូវពាក្យបណ្តឹង រដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងទៅអ្នកប្តឹងថា ពាក្យបណ្តឹងរបស់ខ្លួនត្រូវបានទទួលស្គាល់ថាត្រឹមត្រូវ ឬបដិសេធ ឬរក្សាទុកសម្រាប់ពិចារណានៅពេលក្រោយ ។ រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត ដែលកំណត់ដោយអនុក្រឹត្យមានសិទ្ធិឱ្យអ្នកប្តឹងបង់ប្រាក់ធានា ឬតម្រូវឱ្យមានការធានា ដែលមានតម្លៃស្មើនឹងប្រាក់កក់គ្រប់គ្រាន់សម្រាប់ការពារ អ្នកនាំចូល អ្នកទទួល អ្នកនាំចេញ និងអាជ្ញាធរមានសមត្ថកិច្ច ។ ប្រាក់ធានា ឬការធានាដែលមានតម្លៃស្មើប្រាក់កក់នេះ ត្រូវបានកំណត់តាមរបៀប និងបែបបទដែលមិនត្រូវឱ្យរារាំងដល់ការអនុវត្តនីតិវិធីនេះដោយមិនសមហេតុផល ។

រដ្ឋបាលគយ និងរដ្ឋាករត្រូវព្យួរទុកនូវការធ្វើបែបបទទំនិញ ដែលមានទាក់ទងនឹងពាក្យបណ្តឹង (ការព្យួរទុកនេះមិនឱ្យលើស ១០ថ្ងៃ(ថ្ងៃធ្វើការ)) ។ រដ្ឋបាលគយ និងរដ្ឋាករត្រូវជូនដំណឹងភ្លាមទៅអ្នកនាំចូល និងអ្នកប្តឹងអំពីការព្យួរទុកនូវការធ្វើបែបបទទំនិញហើយត្រូវបញ្ជាក់ពីមូលហេតុនៃការព្យួរទុកនេះផង ។ រដ្ឋបាលគយ និងរដ្ឋាករត្រូវជូនដំណឹងពីឈ្មោះ និងអាសយដ្ឋាននៃអ្នកប្តឹង ដល់អ្នកនាំចូលផងដែរ ។

រយៈពេលមិនលើស ១០ថ្ងៃ (ថ្ងៃធ្វើការក្រោយពីអ្នកប្តឹងទទួលបានពត៌មានពីការឃាត់ទំនិញ) រដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរ មិនបានអនុវត្តវិធានការបណ្តោះអាសន្នដើម្បីពន្យាការព្យួរទុកទំនិញនោះ ទំនិញទាំងនោះត្រូវបានដោះលែង ។ ក្នុងករណីសមស្រប ករណីពន្យាអាចពន្យាបាន ១០ថ្ងៃទៀត នៃថ្ងៃធ្វើការ ។

អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ មានសិទ្ធិសម្រេចឱ្យអ្នកប្តឹង សងអ្នកនាំចូល អ្នកទទួលទំនិញ អ្នកនាំចេញ នូវសំណងសមស្របចំពោះការខូតខាតរបស់ពួកគេ ដែលបណ្តាលមកពីការឃាត់ ឬព្យួរទុកនូវទំនិញទាំងនោះ ។ ក្នុងករណីភាគីណាមួយមិនសុខចិត្ត អាចប្តឹងទៅតុលាការ ។

រដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ម្ចាស់សិទ្ធិ អ្នកនាំចូល អ្នកនាំចេញ ពិនិត្យទំនិញដែលបានព្យួរទុកតាមបែបបទគយ និងដកយកនូវគំរូ ដើម្បីពិនិត្យសាកល្បង និងវិភាគក្នុងគោលបំណងបញ្ជាក់ឱ្យបានដឹងថា ទំនិញនោះ ពាក់ម៉ាកក្លែងក្លាយ ឬមិនក្លែងក្លាយ ។

នៅពេលដឹងថា ទំនិញពាក់ម៉ាកក្លែងក្លាយ រដ្ឋបាលគយ និងរដ្ឋាករ អាចជូនពត៌មានទៅកាន់ម្ចាស់សិទ្ធិនូវឈ្មោះ អាសយដ្ឋានអ្នកនាំចេញនាំចូល អ្នកទទួល និងបរិមាណទំនិញ ។ ដោយមិនឱ្យប៉ះពាល់ដល់ការការពារនូវពត៌មានសម្ងាត់ រដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច អាចផ្តល់ឱ្យម្ចាស់សិទ្ធិ នូវច្បាប់ចម្លងនូវឯកសារនៃឯកសារទំនិញទាំងនោះ ។

### ២.៣.២ ទោសប្បញ្ញត្តិ

សេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម អាចជាកម្មវត្ថុនៃបណ្តឹងតវ៉ាទៅកាន់តុលាការមានសមត្ថកិច្ចបានដោយភាគី ។ ការជំទាស់ និងសេចក្តីសម្រេច អាចដាក់បណ្តឹងទៅតុលាការនៅក្នុងរយៈពេល ៣ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច[៣៩] ។

ការកម្រិតទោសប្បញ្ញត្តិនៃបទល្មើសទាក់ទងការចុះបញ្ជីមានដូចខាងក្រោម៖

ទោសពិន័យ ពី១លានរៀល ទៅ៥លានរៀល ឬ/និងទោសពន្ធនាគារពី១ខែ ទៅ៦ខែ ចំពោះជនណាដែលផ្តល់ពត៌មានមិនពិត ដល់មន្ត្រីកាន់កាប់បញ្ជី ក្នុងការដាក់ពាក្យស្នើសុំបណ្តឹងជំទាស់ ឬឯកសារដទៃ ដែលបានតម្កល់ទុក ទាក់ទិននឹងការសុំចុះបញ្ជី ការកែតម្រូវនៃការចុះបញ្ជី ការចុះបញ្ជីសារជាថ្មី ការលុបចោលនូវការចុះបញ្ជីម៉ាក ពាណិជ្ជនាម ឬកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ ដែលទាក់ទងនឹងម៉ាក ។

ទោសពិន័យ ពី១លានរៀល ទៅ២០លានរៀល ឬ/និងទោសពន្ធនាគារពី១ឆ្នាំ ទៅ៥ឆ្នាំ ចំពោះជនណាដែល៖ (១)ក្លែងបន្លំពាណិជ្ជសញ្ញា សេវាសញ្ញា ម៉ាកសមូហភាព ឬពាណិជ្ជនាមរបស់

[៣៩] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, នស/រកម/០២០២/០០៦, ០៧.កុម្ភៈ.២០០២, មាត្រា៦២។

សហគ្រាសផ្សេងៗ ដែលបានចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងមាត្រា ១១ ត្រង់ចំណុច "ខ" (២)នាំចូល លក់ ប្រកាសលក់ ឬមានបំណងលក់ដោយចេតនានូវទំនិញដែលមានម៉ាកក្លែងបន្លំ ឬមានចេតនាផ្តល់សេវាចំពោះសេវាសញ្ញា ម៉ាកសមូហភាព ឬពាណិជ្ជនាម ដែលបានក្លែងបន្លំនោះ (៣)ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេឡើង ទាំងទោសពិន័យ និងទោសដាក់ពន្ធនាគារ ។

ទោសពិន័យពី ៥លានរៀល ទៅ ១០លានរៀល ឬ/និងទោសដាក់ពន្ធនាគារពី ១ខែ ទៅ១ឆ្នាំ ចំពោះជនណាដែល៖ (១)ធ្វើត្រាប់តាមពាណិជ្ជសញ្ញា សេវាសញ្ញា ម៉ាកសមូហភាព ឬពាណិជ្ជនាមរបស់សហគ្រាសមួយ ដែលបានចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធ្វើឱ្យការមានបំភ័ន្តដល់សាធារណជនឱ្យជឿថា ពាណិជ្ជសញ្ញា សេវាសញ្ញា ម៉ាកសមូហភាព ឬពាណិជ្ជនាមទាំងនោះ ជារបស់សហគ្រាសមួយផ្សេងទៀត ដូចមានចែងមាត្រា ២៣ (២)អ្នកនាំចូល អ្នកលក់ ប្រកាសលក់ ឬមានបំណងលក់ដោយចេតនានូវទំនិញដែលមានម៉ាកត្រាប់តាមគេ (៣) ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេឡើងទាំងទោសពិន័យ និងទោសពន្ធនាគារ ។

ទំនិញទាំងឡាយដែលនាំចូល លក់ ផ្តល់ឱ្យសម្រាប់លក់ ឬមានគោលបំណងលក់ដោយបំពានច្បាប់នូវទំនិញដែលមានម៉ាកក្លែងបន្លំ ទំនិញទាំងនោះត្រូវបានរឹបអូស ឬបំផ្លាញចោលតាមសេចក្តីសម្រេចរបស់តុលាការ ។

# ជំពូក ៣
# ពិភាក្សាលើនីតិវិធីរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក

## ៣.១ ពិភាក្សាលើលក្ខខណ្ឌនៃធាតុនីត្យានុកូល

ជាគោលការណ៍នីតិវិធីរដ្ឋបាលក្នុងការចុះបញ្ជីម៉ាកនៅប្រទេសកម្ពុជា ជាកម្លាំងចលករមួយដ៏សំខាន់សម្រាប់រក្សាទាំងស្រុងនូវម៉ាកដែលពាណិជ្ជករខិតខំបង្កើត ទៅជាទ្រព្យសម្បត្តិដែលមានតម្លៃសម្រាប់គាត់ បើទោះជាវាមានរយៈពេលកំណត់ក៏ដោយក្តី ។ កិច្ចការពារម៉ាកតាមរយៈការចុះបញ្ជីនេះ អាចធ្វើឱ្យពាណិជ្ជករអាចប្រើប្រាស់នូវសក្តានុពលអស់នៃវិញ្ញាបនបត្រម៉ាករបស់ខ្លួន ក្នុងរូបភាពមួយច្បាស់លាស់ ម្យ៉ាងវិញទៀតម៉ាកដែលបានចុះបញ្ជីរួចក៏អាចចរាចរណ៍ក្នុងទីផ្សារដោយជំនឿចិត្ត និងធានាដោយច្បាប់ទៀតផង ។

តួយ៉ាងច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់របស់ប្រទេសកម្ពុជាឆ្នាំ២០០២ ជាគោលសម្រាប់ធានារាល់ការក្លែងបន្លំ ឬអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ទាំងឡាយ ដែលប៉ះពាល់ដល់ពាណិជ្ជករជាម្ចាស់ម៉ាកបានចុះបញ្ជីរួច ។ ចំពោះម៉ាកដែលទាក់ទងនឹងទំនិញ ឬសេវាដែលបានចុះបញ្ជីរួចហើយ សិទ្ធិក្នុងការប្រើប្រាស់ម៉ាកនោះដោយជនណាមួយក្រៅពីម្ចាស់ដើម ត្រូវមានការយល់ព្រមពីម្ចាស់ដើមជាមុនសិន នេះដោយយោងតាមបទប្បញ្ញត្តិមាត្រា១១ ចែងអំពីសិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាក ម្ចាស់ដើមនៃម៉ាកក៏មានសិទ្ធិប្តឹងទៅតុលាការ ប្រឆាំងនឹងជនណាម្នាក់ដែលប្រើប្រាស់ដោយរំលោភនូវម៉ាករបស់ខ្លួនដោយគ្មានការយល់ព្រមពីម្ចាស់ដើម ។ ម្ចាស់ដើមនៃម៉ាកក៏មានសិទ្ធិប្តឹងផងដែរចំពោះការប្រើប្រាស់នូវសញ្ញាដែលប្រហាក់ប្រហែលនឹងម៉ាកដែលខ្លួនបានចុះបញ្ជីរួចហើយ និងការប្រើប្រាស់ម៉ាកដែលទាក់ទិននឹងទំនិញ និងសេវា ដែលប្រហាក់ប្រហែលទៅនឹងទំនិញ ឬសេវានៃម៉ាកដែលចុះបញ្ជីរួចហើយនោះហើយដែលបណ្តាលឱ្យមានការភ័ន្តច្រឡំជាសាធារណៈ ។ សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាកនឹងមិនរាប់បញ្ចូលនូវការដាក់លក់ទំនិញនៅលើទីផ្សារក្នុងប្រទេសកម្ពុជា ដោយម្ចាស់ដែលបានចុះបញ្ជី ឬដោយមានការយល់ព្រមពីម្ចាស់ម៉ាកនោះទេ ។

ផ្ទុយទៅវិញ ក្រសួងពាណិជ្ជកម្មក៏មានសិទ្ធិក្នុងការលុបចោលម៉ាកដែលបានចុះបញ្ជីរួចហើយក្នុងករណីដែលអ្នកសុំចុះបញ្ជីមិនបានដាក់ពាក្យស្នើសុំចុះបញ្ជីសារជាថ្មីនូវម៉ាក ដែលបានចុះបញ្ជីរួចយឺតយ៉ាវក្នុងការចុះបញ្ជីសារជាថ្មីត្រឹមតែរយៈពេល ០៦ខែ ។ ម្ចាស់ម៉ាកស្នើសុំលុប ក្នុងរយៈពេល៩០ថ្ងៃម្ចាស់ម៉ាកមិនគោរពលក្ខខណ្ឌ ម្ចាស់ម៉ាកលែងមានអាសយដ្ឋាននៅក្នុងប្រទេសកម្ពុជា ម្ចាស់គ្មានភស្តុតាងបញ្ជាក់ពីម៉ាកដោយស្របច្បាប់ និងម៉ាកចុះបញ្ជីរួចប្រហាក់ប្រហែល ឬដូចគ្នាទៅនឹងម៉ាកល្បី ក៏មន្ត្រីកាន់កាប់បញ្ជី នៃក្រសួងពាណិជ្ជកម្មមានសិទ្ធិលុបចេញពីបញ្ជីផងដែរ ។

ចំពោះម៉ាកដែលចុះបញ្ជីរួច មិនបានប្រើប្រាស់សោះក្នុងរយៈពេល ០៥ឆ្នាំ ក៏ត្រូវលុបចេញពីបញ្ជីដែរ ។ ប្រសិនម្ចាស់ម៉ាកបង្ហាញថា កាលៈទេសៈពិសេសបានរារាំងការប្រើប្រាស់ម៉ាក ហើយគ្មានបំណងមិនប្រើ ឬបោះបង់ចោលម៉ាកនោះទេ ម៉ាកនោះនឹងមិនត្រូវបានលុបចោលចេញពីបញ្ជីឡើយ ។ ជនណាដែលពាក់ព័ន្ធអាចស្នើសុំឱ្យមន្ត្រីកាន់កាប់បញ្ជី លុបម៉ាកចេញពីបញ្ជី ០១ខែ មុនកាលបរិច្ឆេទ ០៥ឆ្នាំ ឬក្រោយកាលបរិច្ឆេទនេះ ។

### ៣.២ ពិនិត្យលើផ្នែករដ្ឋបាល

ក្រសួងពាណិជ្ជកម្មមានតួនាទី និងភារកិច្ចទាក់ទងនឹងនីតិវិធីចុះបញ្ជីម៉ាក និងគ្រប់គ្រងម៉ាកដែលបានចុះបញ្ជីរួចហើយ ហើយក្រសួងបានប្រកាសបង្កើត ស្ថាប័នមួយឈ្មោះ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលមានសមត្ថកិច្ចកាន់កាប់បញ្ជីម៉ាក ។

ក្នុងនីតិវិធីចុះបញ្ជីម៉ាកយើងសង្កេតឃើញថា នាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្មមានតួនាទីសំខាន់ក្នុងការសម្របសម្រួលនីតិវិធី ពិសេសនៅក្នុងចេញពីវិញ្ញាបនបត្រដើម្បីធានានូវសិទ្ធិលើម៉ាករបស់អ្នកស្នើសុំជាម្ចាស់ម៉ាក ហើយថែមទាំងជាស្ថាប័នដែលអាចរកប្រាក់ចំណូលដល់រដ្ឋផងដែរ ។ ការត្រួតពិនិត្យ និងវិនិច្ឆ័យលើម៉ាក ក្នុងដំណើរការប្រព្រឹត្តទៅនៃការចុះបញ្ជីម៉ាកក៏ជាកាតព្វកិច្ចសំខាន់មួយរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញាផងដែរ ដោយសារវាប្រឈមមុខនឹងការកើនឡើងច្រើនឥតឈរនូវទំនើបកម្មនៃការស្វែងរករបកគំហើញថ្មីនៅពិភពលោកបច្ចុប្បន្ន ហើយកម្ពុជាជាប្រទេសសហភាពក្នុងអនុសញ្ញាទីក្រុងប៉ារីសផង ទើបធ្វើការទំនួលខុសត្រូវក្នុងការចេញវិញ្ញាបនបត្ររបស់មន្ត្រីកាន់កាប់បញ្ជីក្នុងនាយកដ្ឋានកម្មសិទ្ធិបញ្ញាធានាបានប្រសិទ្ធភាព និងគុណតម្លៃជូនម្ចាស់ម៉ាក និងបណ្តាប្រទេសសហភាពអនុសញ្ញាផ្សេងៗផងដែរ ។

### ៣.៣ ចំណុចខ្លាំង និងចំណុចខ្សោយនៃការចុះបញ្ជីម៉ាក

ម៉ាកដែលបានចុះបញ្ជីរួច ទទួលបានកិច្ចការពារពីច្បាប់ដែលធានាឱ្យការប្រកបអាជីវកម្មមានកំណើនពាណិជ្ជកម្មជាអតិបរិមា ទាំងឧស្សាហកម្មខ្នាត់តូច និងមធ្យមផងប្រកបដោយការគាំពារត្រឹមត្រូវ ដូចដែលបានលើកឡើងខាងលើ ប្រសិនបើម្ចាស់ម៉ាកយល់ថា ម៉ាកជាកម្មសិទ្ធិរបស់ខ្លួនមានការរំលោភបំពានខ្លួនអាចដាក់ពាក្យបណ្តឹង ឬស្នើសុំឱ្យមានអន្តរាគមពីនាយកដ្ឋានកម្មសិទ្ធិ ឬឈានដល់ការដាក់ទោសលើជនណាដែលបំពានលើម៉ាកដែលចុះបញ្ជីរួចថែមទៀតផង ។

ការជម្រុញឱ្យពាណិជ្ជករចុះបញ្ជីលើម៉ាកដែលខ្លួនបានបង្កបង្កើតឡើងនេះ គោលដៅឈានទៅដល់មានការអភិវឌ្ឍន៍ប្រទេសជាតិ ឱ្យមានភាពរីកចម្រើន និងទាក់ទាញវិនិយោគទុនដែលមានម៉ាកល្បីៗងាយមកចាប់អារម្មណ៍វិនិយោគក្នុងប្រទេសកម្ពុជា ដោយមានការធានាត្រឹមត្រូវតាមរយៈការចុះបញ្ជីម៉ាក អនុលោមតាមច្បាប់របស់ប្រទេសយើង ។ ប្រទេសយើងថែមទាំងអាចប្រមូលពន្ធអាករលើទំនិញដែលបានចរាចរណ៍ក្នុងទីផ្សារប្រទេសយើងផង និងផ្តល់ឱកាសការងារដល់ប្រជាពលរដ្ឋជាច្រើនផងដែរ ។

ចំណុចមានសារៈសំខាន់មួយ សម្រាប់បណ្តាស្ថាប័នជាតិ និងអន្តរជាតិគឺអាចជម្រុញឱ្យមានសកម្មភាពនៃការប្រកួតប្រជែង ការខិតខំប្រឹងប្រែង និងផ្លែផ្ការបស់ពាណិជ្ជករ អ្នករករបកគំឃើញបច្ចេកទេសផ្សេងៗ តាមរយៈការចុះបញ្ជីដោយរដ្ឋាភិបាលនេះ ជាសេនាធិការដែលមានតួនាទីធានាឱ្យមានការវិនិយោគដោយតម្លាភាព ក្នុងនាមជាម្ចាស់កម្មសិទ្ធិដែលពោរពេញដោយគំនិតច្នៃប្រឌិតក្នុងប្រទេសគោរព និងអនុលោមច្បាប់ផង ។

ក៏ប៉ុន្តែក្នុងករណីម៉ាកមួយដែលកំពុងចរាចរណ៍ក្នុងទីផ្សារ ហើយមានម៉ាកផ្សេងដែលស្រដៀងឬប្រហាក់ប្រហែលចរាចរណ៍ប្រកួតប្រជែងដោយមិនស្មោះត្រង់ ដោយគ្មានវិធានការទប់ស្កាត់ពិតប្រាកដទៀតនោះ គឺជាកត្តាមួយដែលជម្រុញឱ្យមានការអន់ថយនូវចរន្តនៃសន្ទុះពាណិជ្ជកម្មទៅវិញ ឬឈានទៅដល់ការបាក់ទឹកចិត្តគ្មានគំនិតក្នុងច្នៃប្រឌិត វាជាហានិភ័យជាក់ស្តែងដែលត្រូវការការធានាដោយច្បាប់រដ្ឋជាធរមាន ។

មួយវិញទៀត ប្រទេសកម្ពុជាយើងពុំមានស្ថាប័នតុលាការជំនាញក្នុងការដោះស្រាយវិវាទលើកម្មសិទ្ធិម៉ាកនោះទេ នេះជាលក្ខណៈផលវិបាកក្នុងការចាត់ថ្នាក់ឱ្យច្បាស់លាស់នូវទណ្ឌកម្មចំពោះជនដែលហ៊ានក្លែងបន្លំនូវម៉ាក ហើយប្រសិនបើអ្នកក្លែងបន្លំម៉ាកអាចចរាចរណ៍ផលិតផល ដោយសេរីស្របជាមួយ តម្រូវការនៃការប្រើប្រាស់របស់អតិថិជន ដែលត្រូវផលិតផលដែលមានតម្លៃទាបផងនោះ ច្បាស់ជាធ្វើឱ្យវិញ្ញាបនបត្របញ្ជាក់ម្ចាស់ម៉ាកគ្មានតម្លៃទៅវិញ បើគ្មានវិធានការទប់ស្កាត់ទាក់ទងនឹងករណីនេះ ។

# សេចក្តីសន្និដ្ឋាន

ដោយយោងតាមការសិក្សាស្រាវជ្រាវចំពោះប្រធានបទខាងលើ យើងអាចសន្និដ្ឋានបានថា ម៉ាកនៃផលិតផលទាំងអស់ពិតជាមានគុណតម្លៃ និងសារៈសំខាន់ខ្លាំងណាស់ក្នុងការកំណត់សម្គាល់លក្ខណៈខុសៗគ្នានៃម៉ាកទំនិញ និងអាចសម្គាល់ពីគុណភាពនៃទំនិញទាំងអស់ផងដែរ ។

ជាការពិតណាស់ បើទោះជាប្រទេសកម្ពុជាបច្ចុប្បន្នមានច្បាប់ជាតិ កិច្ចព្រមព្រៀង អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិមួយចំនួនស្តីអំពីការពង្រឹង និងការការពារម៉ាកនៃផលិតផលដែលបានចុះបញ្ជីនៅក្នុងក្រសួងពាណិជ្ជកម្មក្តី ក៏អំពើនៃការប្រកួតប្រជែង និងក្លែងបន្លំឈ្មោះនៃផលិតផលផ្សេងៗនូវតែបន្តកើតមានជាបន្តបន្ទាប់ ។ តែបើទោះបីជាយ៉ាងណា ក្រសួងដែលពាក់ព័ន្ធនានា មាននាយកដ្ឋានកម្មសិទ្ធិបញ្ញាដែលជាសេនាធិការនៃក្រសួងពាណិជ្ជកម្ម និងនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ចក្រសួងមហាផ្ទៃ ក្នុងពេលថ្មីៗកន្លងទៅនេះ ក៏បានធ្វើការចុះឆែកឆេរតូបអាជីវករមួយចំនួន ដែលធ្វើអាជីវកម្មលក់ផលិតផលក្លែងក្លាយដែលរួមមានកាបូបយួរដៃ ស្បែកជើង និងខ្សែក្រវ៉ាត់នារីក្លែងក្លាយម៉ាក ដែលធ្វើឲ្យប៉ះពាល់ដល់ក្រុមហ៊ុនគេរកស៊ីស្របច្បាប់ និងប៉ះពាល់ដល់អ្នកប្រើប្រាស់ផងដែរ ។ លទ្ធផលបានរកឃើញកាបូបយួរដៃ និងស្បែកជើងសម្រាប់មនុស្សស្រីជាង១០០កាបូប និង រាប់សិបគូរស្បែកជើង ។ ក្នុងនោះសមត្ថកិច្ចក៏បានអញ្ជើញអាជីវករពាក់ព័ន្ធជាច្រើនតូបមានលក់កាបូប និងស្បែកជើងក្លែងក្លាយបន្លំម៉ាកខាងលើមកធ្វើការអប់រំ ធ្វើកិច្ចសន្យាឱ្យបញ្ឈប់ការលក់របស់ក្លែងក្លាយម៉ាកខាងលើនេះតទៅទៀត ។ ក្រោយពីធ្វើកិច្ចសន្យាអប់រំហើយ ក្រុមអាជីវករជាច្រើនរូបដែលលក់ផលិតផលក្លែងក្លាយ នៅលើទីផ្សារទាំងនោះ ត្រូវបានសមត្ថកិច្ចអនុញ្ញាតឱ្យទៅលក់ដូរធម្មតាវិញ ។ ចំណែកកាបូបរាប់រយ និង ស្បែកជើងជាច្រើនគូរ រួមមានដូចជាខ្សែក្រវ៉ាត់ផងនោះ ត្រូវបានដកហូតយកទៅរក្សាទុកនៅនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច ។ លោកឧត្តមសេនីយ៍ទោ **ឡុង ស្រេង** បានឱ្យដឹងផងដែរថា ការចុះអនុវត្តច្បាប់ស្តីពីការរំលោភកម្មសិទ្ធិបញ្ញា និងក្លែងក្លាយម៉ាកទៅលើផលិតផលនេះ ដោយមានការអនុញ្ញាតពីលោកឧត្តមសេនីយ៍ឯក **ចាន់ វ៉ាន់ធឿន** ប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ចក្រសួងមហាផ្ទៃផងដែរ ដោយយោងទៅតាមពាក្យបណ្តឹងរបស់ក្រុមហ៊ុន M.W METROPOLITAN INTERNATIONAL BRANDS Co., Ltd. ។ លោក **ឡុង ស្រេង** បន្តថា ការចុះអនុវត្តច្បាប់ឆែកឆេររកផលិតផលក្លែងក្លាយនេះ សមត្ថកិច្ចរបស់លោកដកហូតបានកាបូបដៃម៉ាក PEDRO និងម៉ាក CHARLES.KEITH ចំនួន១៥០ និងខ្សែក្រវ៉ាត់ចំនួន៩ ។ ទាំងអស់នេះសបញ្ជាក់យ៉ាងច្បាស់ថា សមត្ថកិច្ចដែលពាក់ព័ន្ធនានា លោកបាននឹងកំពុងតែដុតដៃដុតជើងយ៉ាងសស្រាកសស្រាមក្នុងការទប់ស្កាត់ និងចុះបង្ក្រាបនូវការចរាចរណ៍ផលិតផលមួយចំនួនដែលកំពុងតែក្លែងបន្លំឈ្មោះ នៃផលិតផលពិត ក្នុងន័យដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ។ ដូចនេះបុគ្គលណាដែលបានក្លែងបន្លំនូវ

ផលិតផលដែលម្ចាស់កម្មសិទ្ធិករគាត់បានចុះបញ្ជីរួមហើយ នៅក្រសួងពាណិជ្ជកម្ម គឺជាអំពើដែលខុសច្បាប់ ដូចដែលមានចែងនៅក្នុងនូវច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់ តាមមាត្រ១១ ចំណុចខ ជាដើម ។

ការសិក្សាស្រាវជ្រាវ និងបទបង្ហាញខាងលើ ឃើញថាប្រធានបទ "នីតិវិធីរដ្ឋបាលក្នុងការចុះបញ្ជីម៉ាកនៅប្រទេសកម្ពុជា" ពិតជាទុនយ៉ាងសំខាន់សម្រាប់សិស្សា-និស្សិត ពាណិជ្ជករ អាជីវករ ធ្វើជាទុនក្នុងការសិក្សាបន្ថែមស្តីពីនីតិវិធីការចុះបញ្ជីម៉ាក ពិសេសស្វែងយល់បន្ថែមអំពីការសំយោគន័យសេចក្តីដែលមានក្នុងសៀវភៅរបាយការណ៍កម្មសិក្សាមួយនេះថែមទៀតផង ។ នាយកដ្ឋានកម្មសិទ្ធិ នៃក្រសួងពាណិជ្ជកម្ម សេនាធិការដែលមានតួនាទីសំខាន់សម្រាប់សម្របសម្រួល និងវិនិច្ឆ័យលើម៉ាកណាដែលអាចចុះបញ្ជីបាន នាយកដ្ឋានក៏បានបង្កើតឱ្យមានភាពងាយស្រួលដល់វិនិយោគទុន ម្ចាស់សហគ្រាស ពាណិជ្ជករ អាជីវករ អ្នកជំនួញជាតិ និងអន្តរជាតិ អាចស្វែងរកឯកសារផ្សេងៗទាក់ទងនឹងនីតិវិធីក្នុងការចុះបញ្ជីម៉ាក នៅក្នុងគេហទំព័រហ្វេសប៊ុករបស់ផ្ទាល់របស់នាយកដ្ឋានដើម្បីស្វែងយល់បន្ថែម និងជាទន់សម្រាប់ឈានទៅរកការចុះបញ្ជីម៉ាកលើផលិតផលរបស់ខ្លួនដោយអនុលោមច្បាប់របស់ប្រទេសកម្ពុជា ។

ការចុះបញ្ជីម៉ាកនេះទៀតសោត ជាផលប្រយោជន៍ដ៏ធំធេងសម្រាប់អ្នកមានគំនិតច្នៃប្រឌិតអ្នករុករករបកគំឃើញថ្មី ការពារនូវអត្តសញ្ញាណម៉ាករបស់ខ្លួន ពីជនទាំងឡាយណាដែលមានគំនិតតែងតែបៀតបៀន រំលោភបំពាន់ ប្រព្រឹត្តិអំពើមិនគួរគប្បី ចម្លងស្នាដៃដែលបានកើតចេញអំពីគំនិតច្នៃប្រឌិតរបស់គេ ។ ចំណុចដែលគួរជាទីចាប់បារម្មណ៍ទាក់ទងជុំវិញនឹងប្រធានបទ គឺការកើនឡើងនៃការក្លែងបន្លំម៉ាកផលិតផល នៅក្នុងប្រទេសកម្ពុជាយើងកើនឡើង ដោយឥតឈប់ឈរស្របជាមួយនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងប្រទេសយើង ត្រូវការផលិតផលណាដែលមានតម្លៃទាបផង ធ្វើឱ្យសកម្មភាពនេះក្លាយជាវប្បធម៌ដែលពិបាកខ្លាំងក្នុងការអាចទប់ស្កាត់ ចំណែកឯរាជរដ្ឋាភិបាលកម្ពុជាក៏មានការព្រួយបារម្ភខ្លាំងដែរចំពោះការក្លែងបន្លំនូវផលិតផលទាំងនោះ ដែលអាចបង្កជាបញ្ហាមួយចំនួន ដែលនាំឱ្យផលិតផលក្នុងស្រុកមានការថយចុះ ធ្លាក់តម្លៃនៃផលិតផលបង្កជាគុណវិបត្តិសម្រាប់សាធារណជន ជាពិសេសប្រសិនបើជាផលិតផលប្រើប្រាស់វិញនោះវានឹងផ្តល់ផលប៉ះពាលដល់សុខភាពរបស់ប្រជាពលរដ្ឋ ។

ហេតុដូចនេះបានជាថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម ឯកឧត្តម **ប៉ាន់ សូរសក្តិ** បានថ្លែងដោយព្រមានចាត់វិធានការលើទំនិញបន្លំម៉ាកសញ្ញាទាំងឡាយណា ដែលចរាចរណ៍លក់នៅលើទីផ្សារនាំឱ្យប៉ះពាល់ដល់ទំនិញដើមរបស់ក្រុមហ៊ុន និងប៉ះពាល់ដល់ការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញានៅប្រទេសកម្ពុជា ហើយឯកឧត្តមរដ្ឋមន្ត្រី ក៏បានសំណូមពរដល់ក្រុមហ៊ុនមួយចំនួន សូមឱ្យប្រើប្រាស់ខេមរភាសាលើផលិតផលទាំងអស់ ដើម្បីធ្វើឱ្យមានភាពខុសគ្នាជាមួយផលិតផលនាំចូលខុសច្បាប់

បង្កជាភាពងាយស្រួលដល់មន្ត្រីចាំកាំកុងត្រូលអាចធ្វើការដេកហូតផលិតផលទាំងអស់នោះនៅតាមទីផ្សារនានាបាន ។ ស្របតាមវិធានការច្បាប់ និងការចុះបង្ក្រាបរបស់អាជ្ញាធរមានសមត្ថកិច្ច និងបុគ្គលពាក់ព័ន្ធ យើងខ្ញុំជឿជាក់ថា ការក្លែងបន្លំនូវផលិតផល/សេវា ម៉ាក និងឈ្មោះទំនិញមួយចំនួននិងត្រូវបានកាត់បន្ថយ និងអាចឈានដល់ការលុបបំបាត់ ហើយធានាមកវិញនូវគុណភាព និងសេចក្តីថ្លៃថ្នូរសម្រាប់សង្គមជាតិទាំងមូល ។

# អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងបទបង្ហាញស្តីពី នីតិវិធីរដ្ឋបាលក្នុងការចុះបញ្ជីម៉ាកនៅកម្ពុជា ខ្ញុំទាំងពីរនាក់ ពិតជាមានសេចក្តីរីករាយ រំភើប ដោយបានសិក្សាស្វែងយល់នូវចំណុចនីមួយៗ នៃប្រធានបទខាងលើ ហើយពួកខ្ញុំបានសង្កេតថា ការក្លែងបន្លំនៃម៉ាកផលិតផល និងទំនិញមួយចំនួន មិនមែនដោយសារផលិតផលទាំងនោះមិនបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងពាណិជ្ជកម្ម តាមរយៈនាយកដ្ឋានកម្មសិទ្ធិបញ្ញាទេ តែដោយសារភាពឆក់ល្វែងរបស់ជនមួយចំនួនដែលមានគំនិតទុច្ចរិត និងដោយសារការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ នូវមានកម្រិតនូវឡើយ ។ ទាំងនេះវាអាចជាជ្រុងមួយនៃហេតុផលក្នុងការដែលអាចធ្វើឱ្យការក្លែងបន្លំនោះកើតឡើង ។

ខ្ញុំទាំងពីរនាក់មាននូវគំនិតដ៏តូចមួយ ក្នុងការរួមចំណែកដើម្បីការការពារអំពើរំលោភបំពានម៉ាកនៅកម្ពុជាគឺ ៖

*១. ចំពោះម្ចាស់ម៉ាក ឬម្ចាស់ពាណិជ្ជករ*

- គួរយល់ថា ម៉ាកគឺជាទ្រព្យសម្បត្តិមួយដែលមានតម្លៃមិនគួរមើលរំលង ហើយម្ចាស់ម៉ាក ឬពាណិជ្ជករគួរតែយកផលិតផលរបស់ខ្លួនទៅចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ដើម្បីជៀសវាងពីការក្លែងបន្លំពីសំណាក់ជនដទៃ និងដើម្បីមានសិទ្ធិគ្រប់គ្រាន់ក្នុងកិច្ចការពារផលិតផរបស់ខ្លួនទៅតាមផ្លូវច្បាប់ ។
- គួរជ្រើសរើសម៉ាកណាដែលមិនមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ជាពិសេសមិនប៉ះពាល់ដល់សីលធម៌ សុជីវធម៌ សម្រាប់សង្គមខ្មែរ ។
- បើមានករណីណាមួយ មានការរំលោភបំពានចំពោះផលិតផល ឬទំនិញរបស់ម្ចាស់អាជីវករជាដើម ម្ចាស់អាជីវករផ្ទាល់គួរដាក់ពាក្យមកក្រសួងពាណិជ្ជកម្ម មាននាយកដ្ឋានកម្មសិទ្ធិបញ្ញា ដើម្បីក្រសួងមានសមត្ថកិច្ចនឹងបានចាត់វិធានការតាមផ្លូវច្បាប់ ដើម្បីទប់ស្កាត់ រារាំងកុំអោយការក្លែងបន្លំទាំងនោះបន្តកើតនិងកើនឡើង ។

*២. អាជ្ញាធរមានសមត្ថកិច្ច*

- ក្នុងបរិបទសង្គមកម្ពុជានាពេលបច្ចុប្បន្ន ការផ្សព្វផ្សាយច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ក្តី និងបទដ្ឋានគតិយុត្តិមួយចំនួនទៀតក្តី ហាក់ដូចជានូវមានកម្រិតនូវឡើយ ដោយឡែកការស្វែងយល់របស់ប្រជាពលរដ្ឋទៀតសោតក៏ពុំមានបានយល់ជ្រួតជ្រាបនិងខ្លឹមសារច្បាប់ ហេតុនេះអាជ្ញាធរដែលជាអ្នកតំណាងក្នុងការផ្សព្វផ្សាយច្បាប់គួរមានយន្តការក្នុងការផ្សព្វផ្សាយអោយបានធំទូលាយជាងនេះ ។

- វិះរកវិធីសាស្ត្រក្នុងការការពារទប់ស្កាត់ ទាំងការនាំចូលផលិតផលខុសច្បាប់ និងផលិតផលនៅក្នុងស្រុកព្រោះថាកាលបច្ចេកវិទ្យារីកចម្រើន វិធីសាស្ត្រក្នុងការក្លែងបន្លំទាំងនោះកាន់តែងាយស្រួលដល់ជនទុច្ចរិត ។
- ក្នុងការដោះស្រាយបណ្តឹងទាក់ទងនិងការរំលោភបំពានម៉ាក អាជ្ញាធរមានសមត្ថកិច្ចគួរអនុលោមតាមច្បាប់ និងសម្របសម្រួលភាគីទាំងពីរអោយស្រុះស្រួលគ្នាដោយសន្តិវិធី និងស្របតាមបទដ្ឋានច្បាប់ជាដើម ។

ស្របតាមគំនិតដ៏ស្លួចស្តើងខាងលើនេះ ខ្ញុំទាំងពីរនាក់សង្ឃឹមថា នឹងបានជាជ្រុងមួយនៃគំនិតក្នុងការរួចចំណែកដើម្បីការពារការក្លែងបន្លំនូវផលិតផល ទំនិញ និងអាចជាគំនិតក្នុងការដាស់តឿនស្មារតីអ្នកអនុវត្តន៍អោយកាន់តែមានការប្រុងប្រយ័ត្នបន្ថែម និងបន្តការការពារផលប្រយោជន៍ម្ចាស់អាជីវករដែលស្របតាមច្បាប់ និងអាចរក្សាគុណតម្លៃសម្រាប់សង្គមកម្ពុជាទាំងមូល ។

# ឯកសារពិគ្រោះ

១. ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២

២. ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នស/រកម/០១១៤/០០៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤

៣. កិច្ចព្រមព្រៀងទីក្រុងនីស ដែលចែងអំពីចំណាត់ថ្នាក់អន្តរជាតិនៃទំនិញ និងសេវាកម្ម សម្រាប់គោលបំណងនៃការចុះបញ្ជីម៉ាក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥៧

៤. អនុសញ្ញាទីក្រុងប៉ារីសស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្មចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៨៨៣

៥. អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់ លេខ ៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦

៦. ប្រកាសរួមលេខ ១២១៧ សហវ.ប្រក ចុះថ្ងៃ២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៧. ប្រកាសស្តីពីការទទួលស្គាល់អ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីលេខ ២៥៨ ពណចបព.ប្រក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧

៨. ប្រកាសស្តីពីបែបបទ និងនីតិវិធី ចុះក្នុងបញ្ជីពាណិជ្ជកម្មលេខ ១៩២ ពណចបព.ប្រក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥

៩. ប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកវិញ្ញាតកម្មលេខ ២៩៣ ពណកសប.ប្រក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦

១០. នី វិចិត្រ, នីតិកម្មសិទ្ធិបញ្ញា (ភ្នំពេញ៖ ក្រុមហ៊ុនមេធាវី អេចប៊ីអេស ២០១៣)

១១. ឥន យឿន និងអ៊ុក វណ្ណារ័ត្ន, នីតិកម្មិសិទ្ធិបញ្ញា (ភ្នំពេញ ២០១៣)

១២. http://cambodiaip.gov.kh/TemplateTwo.aspx?parentId=2&menuid=39&childMasterMenuId=29.

១៣. http://cambodiaip.gov.kh/TemplateTwo.aspx?parentId=2&menuid=61&childMasterMenuId=29

១៤. https://www.businessregistration.moc.gov.kh/laws-and-regulations/

១៥. http://bizdoctors.asia/ចង់ចុះបញ្ជីក្រុមហ៊ុន៕